ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យៈករណីសិក្សាស្រុកព្រៃកប្បាសខេត្តតាកែវ

# MANAGEMENT OF TEACHING AND LEARNING ENGLISH AT THE HIGH SCHOOL LEVEL: A CASE STUDY FOR PREY KABBAS DISTRICT, TAKEO PROVINCE.

ឆេង ថុល

CHHENG THOL

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

**ក្រសួងអប់រំ យុវជន និងកីឡា**

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យៈករណីសិក្សាស្រុកព្រៃកប្បាសខេត្តតាកែវ

MANAGEMENT OF TEACHING AND LEARNING ENGLISH AT THE HIGH SCHOOL LEVEL: A CASE STUDY FOR PREY KABBAS DISTRICT, TAKEO PROVINCE.

**ឆេង ថុល**

CHHENG THOL

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល**

**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ជំនាន់ទី៩**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២០-២០២២**

**គ្រូណែនាំបង្គោលៈ លោកគ្រូ ប៉ូ ប៊ុន្លន**

**គ្រូណែនាំរងៈ លោកគ្រូបណ្ឌិត សោន វណ្ណៈ**

# **សេចក្ដីអះអាងរបស់បេក្ខជន**

ខ្ញុំបាទឈ្មោះ **ឆេង ថុល** សូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងទាំងស្រុងថា «**ការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យៈករណីសិក្សាស្រុកព្រៃកប្បាសខេត្តតាកែវ**» ដែលត្រូវបានស្រាវជ្រាវសម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ហើយស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះឬនៅសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ម្យ៉ាងទៀតពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារណាមួយដែលត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាត្រូវបានស្រាវជ្រាវនិងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០២២

**ហត្ថលេខាបេក្ខជន**



**ឆេង ថុល**

# លិខិតបញ្ជាក់

លោកគ្រូ **ម៉ូ ម៉ិន្តន** ជាគ្រូណែនាំបង្គោល

លោកបណ្ឌិត **សោន វណ្ណៈ** ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ឆេង ផុល** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវស្តីពី«**ការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យៈករណីសិក្សាស្រុកព្រៃកប្បាសខេត្តតាកែវ**» ពិតប្រាកដមែន។

ថ្ងៃអាទិត្យ ១៣កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០២២





.....................................

**លោកគ្រូ ម៉ូ ម៉ិន្តន**

អនុប្រធានការិយាល័យសិក្សានៅវិទ្យាស្ថានជាតិអប់រំ

.....................................

**លោកបណ្ឌិត សោន វណ្ណៈ**

គ្រូឧទ្ទេសនៅវិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៧០២៥ អយក.ខ៩ន

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំង ជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ឧទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | ឧទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម | យក់ ង៉ុយ | ឧទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម | លាង សេងហាក់ | ឧទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម | ម៉ក់ ង៉យ | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | សមាជិក |
| ៧-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-ឯកឧត្តមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នូវ វ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៥-លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៦-លោកបណ្ឌិត | អៃ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ១៧-លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ...៣៧០២៦...អយក.ឧទន**

**(ការសម្ងាត់)**

## លិខិតឧទ្ទេសនាម

យោងៈ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោកបណ្ឌិត | ឡាយ សុវិជ្ជា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៥-លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៨-លោកបណ្ឌិត | ឈិញ នីដា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៩-លោកបណ្ឌិត | អ៊ុំ ចាន់ចំណាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | មឿន លិនណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | គួយ សូគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោក | ប៉ូ ប៊ុន្នួន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | សឿ សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០.លោក | ឋាច់ សន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១.លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២.លោកស្រី | សេង សច្ចា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣.លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤.លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥.លោកស្រី | ឯម សុភាលក្ស្មី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

# លិខិតថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឆេង ថុល** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៃវិទ្យាស្ថានជាតិអប់រំ។

## សូមថ្លែងអំណរគុណជាអនេកប្បការជូនចំពោះ

-លោកឪពុក **ឆាំង សេង** និងអ្នកម្តាយ **ចិល គាំ** ដែលបានផ្តល់កំណើតនិងបានចិញ្ចឹមបីបាច់ថែរក្សារូបកូនដោយមិនគិតពីការលំបាកព្រមទាំងបានពុះពារគ្រប់ឧបសគ្គគ្រប់បែបយ៉ាងទាំងអស់ធ្វើយ៉ាងណាអោយរូបកូនទទួលបានការសិក្សាអប់រំដូចកូនគេដ៏ទៃទៀតដែរ។ លើសពីនេះទៅទៀតលោកតែងតែបានផ្តល់នូវដំបូន្មានល្អៗ គ្រប់ពេលវេលាក្នុងគោលបំណងខ្លាចកូនដើរផ្លូវមិនល្អ ក្លាយជាមនុស្សឥតប្រយោជន៍ ។

-បងស្រី **ឆេង ថន** ដែលបានមើលថែរូបខ្ញុំតាំងពីតូចបន្ទាប់ពីលោកឪពុកបានចែកឋានទៅថែមទាំងបានមើលថៃខ្ញុំដោយមិនគិតពីការលំបាកគ្រប់យ៉ាងរួមគ្នាជាមួយអ្នកម្តាយដើម្បីជួយជ្រោមជ្រែងខ្ញុំអោយបានទទួលការអប់រំពេញលេញ និងជួយសម្រេចក្តីស្រម៉ៃរបស់ខ្ញុំដែលចង់ក្លាយខ្លួនជាគ្រូភាសាអង់គ្លេសមួយរូបថែមទៀតផង។

**-ឯកឧត្តមថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា** ដែលបានរៀបចំបង្កើតឱ្យមានថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំសម្រាប់បុគ្គលិកអប់រំនេះឡើង ដែលធ្វើអោយខ្ញុំមានឪកាសក្នុងការសិក្សាស្វែងយល់បន្ថែមដើម្បីពង្រឹងនិងព្រីកចំណេះដឹងរបស់ខ្លួនស្របទៅតាមបរិបទថ្មីនៃសង្គមនាពេលបច្ចុប្បន្នក៏ដូចជាបានដកស្រង់យកបទពិសោធន៍ល្អៗពីលោកគ្រូអ្នកគ្រូដែលជាសាស្ត្រាចារ្យនិងមិត្តរួមជំនាន់ដែលជាគ្រូបង្រៀនមកពីបណ្តាខេត្តនានា។

-លោកគ្រូ **ម៉ូ ម៉ុន្លន** អនុប្រធានការិយាល័យសិក្សានៃវិទ្យាស្ថានជាតិអប់រំ ដែលជាសាស្ត្រាចារ្យណែនាំបង្ហាល លោកបានឆ្លៀតពេលវេលាដ៏មានតម្លៃរបស់លោកមកផ្តល់ជាគំនិតល្អៗ ឯកសារពាក់ព័ន្ធនិងវិធីសាស្ត្រផ្សេងៗ ដើម្បីជួយជ្រោមជ្រែងក្នុងការសរសេរនិក្ខេបបទស្រាវជ្រាវរបស់ខ្ញុំអោយបានសម្រេចដល់គោលដៅដូចបំណង។

-លោកគ្រូបណ្ឌិត **សោន ចន្ធ្នា:** គ្រូឧទ្ទេសនៅវិទ្យាស្ថានជាតិអប់រំ ដែលជាសាស្ត្រាចារ្យណែនាំរង ដែលបានឆ្លៀតពេលដ៏មានតម្លៃរបស់លោកគ្រូក្នុងការផ្តល់គំនិតណែនាំ និងផ្តល់ទាំងកម្លាំងកាយកម្លាំងចិត្ត បញ្ញាស្មារតី បច្ចេកទេស វិធីសាស្ត្រផ្សេងៗ។

-ឯកឧត្តម បណ្ឌិត លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ និង ជាសាស្ត្រាចារ្យទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ ដែលបានខិតខំអស់ពីកម្លាំងកាយចិត្ត ក្នុងការផ្តល់ពុទ្ធិ ឯកសារសិក្សា ឥរិយាបថ ពិសេសផ្តល់ជាទ្រឹស្តី បទពិសោធន៍ល្អៗ ដែលទាំងនេះជាចំណេះដឹងមួយដ៏សំខាន់ និងចាំបាច់បំផុតសម្រាប់អនុវត្ត ព្រមទាំងឆ្លុះបញ្ចាំងពីការអនុវត្តការងារបច្ចុប្បន្ន និងបានសម្របសម្រួលដល់ដំណើរការនៃការបណ្តុះបណ្តាលក្នុងវគ្គនេះប្រកបដោយជោគជ័យ។

-លោកនាយក នាយិកា នាយករង លោកគ្រូ អ្នកគ្រូ នៅតាមគ្រឹះស្ថានសិក្សាតាមគោលដៅស្រាវជ្រាវរបស់ខ្ញុំដែលបានសហការ ចំពោះការចុះស្រាវជ្រាវ និង ការប្រមូលទិន្នន័យរបស់ខ្ញុំ ដើម្បីខ្ញុំយកមកសរសេរនិក្ខេបបទនេះរហូតទទួលបានជោគជ័យ។

-អ្នកគ្រូ **សារី ផល្លី** អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ ដែលបានបានផ្តល់ជាអនុសាសន៍ដ៏មានតម្លៃ ក៏ដូចជាបទពិសោធន៍ និង ឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានជួយអោយខ្ញុំបាទបានប្រឡងជាប់អាហារូបករណ៍ពេញថ្លៃថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំជំនាន់ទី៩បានដោយជោគជ័យ។

-លោកគ្រូ **យន់ យ៉ុខ** ប្រធានការិយាល័យមធ្យមខេត្តតាកែវដែលតែងតែបានផ្តល់យោបល់ក្នុងការដោះស្រាយចំបញ្ហាដែលទាក់ទងជាមួយនិងការសិក្សារបស់ខ្ញុំតាំងពីថ្នាក់បរិញ្ញាបត្ររហូតខ្ញុំប្រឡងជាប់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំបានជោគជ័យ។

-លោកគ្រូ **ឈឹម សុវណ្ណា** នាយកវិទ្យាល័យសមរលោរដែលបានជម្រុញនិងលើកទឹកចិត្តព្រមទាំងជួយសម្រួលកិច្ចការងារលំបាករបស់ខ្ញុំបាទ ដើម្បីអោយខ្ញុំមានឪកាសបានសិក្សាថ្នាក់បរិញ្ញាបត្រនេះរហូតបានជោគជ័យ។

-លោកគ្រូ **ឌុក ឌីកែន** នាយករងវិទ្យាល័យសមរលាវដែលតែងតែជួយខ្ញុំនូវរាល់បញ្ហាផ្សេងៗ ដែលពាក់ព័ន្ធទៅលើផ្នែកបច្ចេកទេសកុំព្យូទ័រនិងលើកទឹកចិត្តអោយខ្ញុំបាទបានខិតខំប្រឹងប្រែងរហូតបាន បញ្ចប់ដោយជោគជ័យ។

ជាទីបញ្ចប់ខ្ញុំបាទ សូមគោរពបួងសួងដល់វត្ថុស័ក្តិសិទ្ធដែលមាននៅក្នុងលោកយើងនេះជួយប្រសិទ្ធិពរជ័យ សិរីបវរមហាប្រសើរជូនចំពោះ អ្នកមានគុណទាំងអស់ខាងលើ ជួបប្រទះតែពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតប្រការណាមួយឡើយ។

# មាតិកា


សេចក្តីអះអាងរបស់បេក្ខជន ........................................................................................ ii

លិខិតបញ្ជាក់ .................................................................................................................. iii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ........................................ iv

លិខិតថ្លែងអំណរគុណ.....................................................................................................viii

បញ្ជីតារាង ...................................................................................................................xviii

បញ្ជីក្រាប........................................................................................................................ xix

មូលន័យសង្ខេប ..............................................................................................................xxii

Abstract ......................................................................................................................... xxv

**ជំពូក១៖ សេចក្តីផ្តើម**.....................................................................................................2

១.១. លំនាំបញ្ហានៃការស្រាវជ្រាវ .........................................................................................2

១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ.......................................................................................5

១.៣. គោលបំណងនៃការស្រាវជ្រាវ.........................................................................................6

១.៤. សំណួរសិក្សាស្រាវជ្រាវ...................................................................................................6

១.៥. សារៈសំខាន់នៃការស្រាវជ្រាវ..........................................................................................6

១.៦. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ...................................................................7

១.៧. រចនាសម្ព័ន្ធស្រាវជ្រាវ .....................................................................................................7

១.៨. កាលបរិច្ឆេទនៃការស្រាវជ្រាវ...........................................................................................9

**ជំពូក២៖ រំលឹកទ្រឹស្តី** ........ 11
២.១. ការសិក្សាពាក្យគន្លឹះ ........ 11
២.២. ការងារគ្រប់គ្រងអប់រំ ........ 12
២.២.១. អត្ថន័យនៃការគ្រប់គ្រង ........ 13
២.២.២. ឋានានុក្រមនៃការគ្រប់គ្រង ........ 13
២.២.៣. មុខងារនៃការគ្រប់គ្រង ........ 14
២.២.៤. តួនាទីនៃការគ្រប់គ្រង ........ 15
២.៣. ការអប់រំភាសាអង់គ្លេសនៅប្រទេសកម្ពុជា ........ 15
២.៣.១. គោលបំណងនៃការសិក្សាភាសាអង់គ្លេស ........ 16
២.៣.២. របាយម៉ោងសិក្សា ........ 17
២.៣.៣. ការអនុវត្តការណែនាំ ........ 17
២.៣.៣.១. វិធីសាស្រ្តបង្រៀន ........ 18
២.៣.៣.២. ការប្រើប្រាស់សម្ភារៈ ........ 18
២.៣.៤. ការវាយតម្លៃ ........ 19
២.៣.៤.១. វិធីវាយតម្លៃ ........ 19
២.៣.៤.២. រូបភាពវាយតម្លៃ ........ 20
**ជំពូក៣៖ វិធីសាស្រ្តស្រាវជ្រាវ** ........ 22

៣.១. គម្រោងវិភាគ ........ 22

៣.១.១. កម្រងសំណួរ ........ 22

ក.កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា ........ 22

ផ្នែកទី១៖ ព័ត៌មានទូទៅ ........ 22

ផ្នែកទី២៖ការយល់ឃើញរបស់គណៈគ្រប់គ្រងសាលាទៅលើមុខវិជ្ជាភាសាអង់គ្លេស........ 23

ផ្នែកទី៣៖ ការគ្រប់គ្រងការបង្រៀននិងរៀនលើមុខវិជ្ជាភាសាអង់គ្លេស ........ 23

ផ្នែកទី៤៖បញ្ហាប្រឈមលើការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេស ........ 24

ខ.កម្រងសំណួរសម្រាប់គ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី១០ ទី១១ និង ទី១២ ........ 24

ផ្នែកទី១៖ ព័ត៌មានទូទៅ ........ 24

ផ្នែកទី២៖ការយល់ឃើញរបស់គ្រូបង្រៀនចំពោះមុខវិជ្ជាភាសាអង់គ្លេស ........ 24

ផ្នែកទី៣៖ ការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេស ........ 25

ផ្នែកទី៤៖បញ្ហាប្រឈមក្នុងការបង្រៀនភាសាអង់គ្លេស ........ 25

គ.កម្រងសំណួរសំរាប់សិស្សានុសិស្សនៅថ្នាក់ទី១០ ទី១១ និង ទី១២ ........ 26

ផ្នែកទី១៖ ព័ត៌មានទូទៅ ........ 26

ផ្នែកទី២៖ការយល់ឃើញរបស់សិស្សានុសិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស ........ 26

ផ្នែកទី៣៖ ការសិក្សាភាសាអង់គ្លេសរបស់សិស្សានុសិស្ស........ 26

ផ្នែកទី៤៖បញ្ហាប្រឈមក្នុងការបង្រៀនភាសាអង់គ្លេស ........ 27

៣.២. ការប្រមូលទិន្នន័យ....................................................................................27

៣.៣. ឧបករណ៍ស្រាវជ្រាវ.......................................................................................29

៣.៤. ការជ្រើសរើសសំណាក ...................................................................................29

៣.៥. ការវិភាគនិន្នន័យ...........................................................................................30

**ជំពូក៤៖ លទ្ធផលស្រាវជ្រាវនិងការពិភាក្សា**.......................................................32

៤.១. គណគ្រប់គ្រងសាលា......................................................................................32

៤.១.១. ព័ត៌មានទូទៅ ...............................................................................................32

៤.១.២. ការយល់ឃើញរបស់គណៈគ្រប់គ្រងសាលាចំពោះមុខវិជ្ជាភាសាអង់គ្លេស .............33

៤.១.២.១. សារៈសំខាន់ភាសាអង់គ្លេសចំពោះការសិក្សានិងការស្រាវជ្រាវ.........................33

៤.១.២.២. សារៈសំខាន់ភាសាអង់គ្លេសចំពោះការងារចិញ្ចឹមជីវិតនាពេលបច្ចុប្បន្ន...............34

៤.១.២.៣. សារៈសំខាន់ភាសាអង់គ្លេសទៅថ្ងៃអនាគត ......................................................35

៤.១.៣. ការគ្រប់គ្រងលើការបង្រៀននិងរៀនលើមុខវិជ្ជាភាសាអង់គ្លេស ............................36

៤.១.៣.១. សេចក្ដីណែនាំស្ដីពីការបង្រៀនភាសាអង់គ្លេស ..................................................36

៤.១.៣.២. សៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេសកម្រិតវិទ្យាល័យ ...........................37

៤.១.៣.៣. ម៉ោងសិក្សាភាសាអង់គ្លេសតាមថ្នាក់នីមួយៗ ...................................................38

៤.១.៣.៤. សមត្ថភាពនិងទេពកោសល្យរបស់គ្រូបង្រៀនភាសាអង់គ្លេស ...........................39

៤.១.៣.៥. កិច្ចតែងការបង្រៀននិងសម្ភារៈឧបទ្ទេសរបស់លោកគ្រូអ្នកគ្រូ ...........................40

៩.១.៣.៦. ការវាយតម្លៃលទ្ធផលសិក្សាភាសាអង់គ្លេសប្រចាំខែរបស់សិស្ស ......................40
៩.១.៣.៧. ការចុះអធិការកិច្ចលើដំណើរការបង្រៀនភាសាអង់គ្លេស ................................42
៩.១.៣.៨. ការសិក្សារបស់សិស្សានុសិស្ស.......................................................................43
៩.១.៤. បញ្ហាប្រឈមលើការគ្រប់គ្រងការបង្រៀននិងរៀនលើមុខវិជ្ជាភាសាអង់គ្លេស.........44
៩.១.៤.១. កត្តាសាលារៀន ..........................................................................................44
៩.១.៤.២. កត្តាគ្រូបង្រៀន ..........................................................................................45
៩.១.៤. ៣.កត្តាសិស្ស...............................................................................................46
៩.១.៤.៤. កត្តាមជ្ឈដ្ឋានជុំវិញនិងសង្គម .......................................................................47
៩.២. គ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី១០ ទី១១ និងទី១២...........................................48
៩.២.១. ព័ត៌មានទូទៅ...................................................................................................48
៩.២.២. ការយល់ឃើញរបស់គ្រូបង្រៀនចំពោះមុខវិជ្ជាភាសាអង់គ្លេស..............................49
៩.២.២.១. សារៈសំខាន់ភាសាអង់គ្លេសចំពោះការសិក្សានិងការស្រាវជ្រាវ.........................49
៩.២.២.២. សារៈសំខាន់ភាសាអង់គ្លេសចំពោះការងាចិញ្ចឹមជីវិត .......................................50
៩.២.២.៣. សារៈសំខាន់ភាសាអង់គ្លេសទៅថ្ងៃអនាគត......................................................51
៩.២.៣. ការគ្រប់គ្រងលើការបង្រៀននិងរៀនលើមុខវិជ្ជាភាសាអង់គ្លេស ............................52
៩.២.៣.១. សេចក្តីណែនាំស្តីពីការបង្រៀនភាសាអង់គ្លេស...................................................52
៩.២.៣.២. សៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេស ...................................................53

៤.២.៣.៣. ម៉ោងសិក្សាភាសាអង់គ្លេសតាមថ្នាក់នីមួយៗ ....................................................54

៤.២.៣.៤. សមត្ថភាពនិងទេពកោសល្យរបស់គ្រូបង្រៀនតាមថ្នាក់នីមួយៗ ........................55

៤.២.៣.៥. កិច្ចតែងការបង្រៀននិងសម្ភារៈឧបទ្ទេសរបស់លោកគ្រូអ្នកគ្រូ ..........................56

៤.២.៣.៦. ការធ្វើតេស្តនិងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ..................................57

៤.២.៣.៧. ការចុះអធិការកិច្ចលើដំណើរការបង្រៀនភាសាអង់គ្លេស .................................58

៤.២.៣.៨. ការសិក្សារបស់សិស្សានុសិស្ស.......................................................................59

៤.២.៤. បញ្ហាប្រឈមលើការបង្រៀននិងរៀនលើមុខវិជ្ជាភាសាអង់គ្លេស ...........................60

៤.២.៤.១. កត្តាសាលារៀន ...........................................................................................60

៤.២.៤.២. កត្តាគ្រូបង្រៀន ...........................................................................................61

៤.២.៤.៣. កត្តាសិស្ស ..................................................................................................62

៤.២.៤.៤. កត្តាមជ្ឈដ្ឋានជុំវិញ .....................................................................................63

៤.៣. សិស្សានុសិស្សភាសាអង់គ្លេសថ្នាក់ទី១០ ទី១១ និងទី១២........................................64

៤.៣.១. ព័ត៌មានទូទៅ ..................................................................................................64

៤.៣.២. ការយល់ឃើញរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស ....................................65

៤.៣.៣. ការបង្រៀននិងរៀនសំរាប់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស.............................66

៤.៣.៣. បញ្ហាប្រឈមសំរាប់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស ......................................67

៤.៤. សរុបលទ្ធផលរួមទាំងគណៈគ្រប់គ្រងសាលា គ្រូបង្រៀនភាសាអង់គ្លេស និង សិស្សានុសិស្ស ..........68
៤.៤.១. ការយល់ឃើញចំពោះមុខវិជ្ជាភាសាអង់គ្លេស..........68
៤.៤.២. ការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេស..........72
**ជំពូក៥៖ សេចក្តីសន្និដ្ឋាននិងសំណូមពរ**..........82
៥.១. សេចក្តីសន្និដ្ឋាន..........82
១. ការយល់ឃើញចំពោះមុខវិជ្ជាភាសាអង់គ្លេស ..........82
២. ការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេស ..........82
៣. បញ្ហាប្រឈមនៅក្នុងការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេស ..........83
៥.២. សំណូមពរ..........84
៥.៣. អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ថែម..........84
ឯកសារយោង..........86
ឧបសម្ព័ន្ធ«ក»..........89
ឧបសម្ព័ន្ធ«ខ»..........94
ឧបសម្ព័ន្ធ«គ»..........99

# បញ្ជីតារាង

តារាងទី1៖កាលបរិច្ឆេទនៃការស្រាវជ្រាវ....................................................................9

តារាងទី2៖របាយម៉ោងសម្រាប់កម្រិតវិទ្យាល័យ ...............................................................17

តារាងទី3៖ព័ត៌មានលំអិតអំពីគណៈគ្រប់គ្រង ....................................................................32

តារាងទី4៖ព័ត៌មានលំអិតអំពីគ្រូបង្រៀនភាសាអង់គ្លេស ...................................................48

តារាងទី5៖បង្ហាញអំពីព័ត៌មានលម្អិតអំពីសិស្ស.................................................................64

# បញ្ជីក្រាប

ក្រាបទី1៖សារៈសំខាន់ភាសាអង់គ្លេសចំពោះការសិក្សានិងការស្រាវជ្រាវ ..........................33

ក្រាបទី2៖សារៈសំខាន់ភាសាអង់គ្លេសចំពោះការងារចិញ្ចឹមជីវិតនាពេលបច្ចុប្បន្ន ................34

ក្រាបទី3៖សារៈសំខាន់ភាសាអង់គ្លេសទៅថ្ងៃអនាគត ......................................................35

ក្រាបទី4៖សេចក្តីណែនាំស្តីពីការបង្រៀនភាសាអង់គ្លេស ..................................................36

ក្រាបទី5៖សៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេសកម្រិតវិទ្យាល័យ ............................37

ក្រាបទី6៖ម៉ោងសិក្សាតាមថ្នាក់នីមួយៗ.........................................................................38

ក្រាបទី7៖សមត្ថភាពនិងទេពកោសល្យរបស់គ្រូបង្រៀនភាសាអង់គ្លេស ............................39

ក្រាបទី8៖កិច្ចតែងការបង្រៀននិងសម្ភារៈឧបទេ្ទសរបស់លោកគ្រូអ្នកគ្រូ ............................40

ក្រាបទី9៖ការវាយតម្លៃលទ្ធផលសិក្សាភាសាអង់គ្លេសប្រចាំខែរបស់សិស្ស .........................40

ក្រាបទី10៖ការចុះអធិការកិច្ចលើដំណើរការបង្រៀនភាសាអង់គ្លេស..................................42

ក្រាបទី11៖ការសិក្សារបស់សិស្សានុសិស្ស.......................................................................43

ក្រាបទី12៖កត្តាសាលារៀន .........................................................................................44

ក្រាបទី13៖កត្តាគ្រូបង្រៀន...........................................................................................45

ក្រាបទី14៖កត្តាសិស្ស..................................................................................................46

ក្រាបទី15៖កត្តាមជ្ឍដ្ឋានជុំវិញនិងសង្គម......................................................................47

ក្រាបទី16៖សារៈសំខាន់ភាសាអង់គ្លេសចំពោះការសិក្សានិងការស្រាវជ្រាវ ........................49

ក្រាបទី17៖សារៈសំខាន់ភាសាអង់គ្លេសចំពោះការងារចិញ្ចឹមជីវិត.......................................50

ក្រាបទី18៖សារៈសំខាន់ភាសាអង់គ្លេសទៅថ្ងៃអនាគត ....................................................51

ក្រាបទី19៖សេចក្តីណែនាំស្តីពីការបង្រៀនភាសាអង់គ្លេស ................................................52

ក្រាបទី20៖សៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេស....................................................53

ក្រាបទី21៖ម៉ោងសិក្សាភាសាអង់គ្លេសតាមថ្នាក់នីមួយៗ....................................................54

ក្រាបទី22៖សមត្ថភាពនិងទេពកោសល្យរបស់គ្រូបង្រៀនតាមថ្នាក់នីមួយៗ.........................55

ក្រាបទី23៖កិច្ចតែងការបង្រៀននិងសម្ភារៈឧបទ្ទេសរបស់លោកគ្រូអ្នកគ្រូ ...........................56

ក្រាបទី24៖ការធ្វើតេស្តនិងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ...................................57

ក្រាបទី25៖ការចុះអធិការកិច្ចលើដំណើរការបង្រៀនភាសាអង់គ្លេស .................................58

ក្រាបទី26៖ការសិក្សារបស់សិស្សានុសិស្ស.......................................................................59

ក្រាបទី27៖កត្តាសាលារៀន ...........................................................................................60

ក្រាបទី28៖កត្តាគ្រូបង្រៀន...............................................................................................61

ក្រាបទី29៖កត្តាសិស្ស.....................................................................................................62

ក្រាបទី30៖កត្តាមជ្ឈដ្ឋានជុំវិញ .......................................................................................63

ក្រាបទី31៖សារៈសំខាន់ភាសាអង់គ្លេស...........................................................................65

ក្រាបទី32៖ការបង្រៀននិងរៀនភាសាអង់គ្លេស ..................................................................66

ក្រាបទី33៖បញ្ហាប្រឈមរបស់សិស្ស...............................................................................67

ក្រាបទី34៖ការយល់ឃើញចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់គណៈគ្រប់គ្រងសាលា........68

ក្រាបទី35៖ការយល់ឃើញចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់គ្រូបង្រៀន .........................68

ក្រាបទី36៖ការយល់ឃើញចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់សិស្សានុសិស្ស...................70

ក្រាបទី37៖ជាការសរុបបញ្ចូលគ្នានៃការយល់ឃើញចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់គណៈ

គ្រប់គ្រងសាលា និង គ្រូបង្រៀនភាសាអង់គ្លេស ............................................................71

ក្រាបទី38៖ការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់គណៈគ្រប់គ្រងសាលា.72

ក្រាបទី39៖ការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់គ្រូបង្រៀន....................73

ក្រាបទី40៖ការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់សិស្សស្សានុសិស្ស ......74

ក្រាបទី41៖ជាការបញ្ចូលគ្នាទាំងគណៈគ្រប់គ្រងសាលា និង គ្រូបង្រៀន ពាក់ព័ន្ធជាមួយនិង ការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេស ..........................................................75

ក្រាបទី42៖បញ្ហាប្រឈមចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់នាយកសាលា........................76

ក្រាបទី43៖បញ្ហាប្រឈមចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់គ្រូបង្រៀន .............................77

ក្រាបទី44៖បញ្ហាប្រឈមចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់សិស្ស....................................78

ក្រាបទី45៖ជាការបញ្ចូលគ្នាទាំងគណៈគ្រប់គ្រងសាលា និង គ្រូបង្រៀន ពាក់ព័ន្ធជាមួយនិង បញ្ហាប្រឈមនៃការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេស....................................79

ក្រាបទី46៖ជាការសរុបបញ្ចូលគ្នាទាំងគណៈគ្រប់គ្រងសាលា គ្រូបង្រៀនភាសាអង់គ្លេស និង សិស្សានុស្ស ពាក់ព័ន្ធជាមួយនិងការយល់ឃើញ ការគ្រប់គ្រងការបង្រៀននិងរៀន និងបញ្ហា ប្រឈម ....................................................................................................................80

# មូលន័យសង្ខេប

មុខវិជ្ជាភាសាអង់គ្លេសជាមុខវិជ្ជាមួយដែលមានសារៈសំខាន់និងជាភាសាទីពីរដែលត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សារបស់រដ្ឋដូចគ្នាទៅនិងមុខវិជ្ជាផ្សេងទៀតដែរ ក្នុងគោលបំណងសំខាន់ដើម្បីរួមចំណែកក្នុងការលើកកម្ពស់គុណភាពអប់រំផ្នែកភាសាអោយកាន់តែរីកចម្រើនថែមទៀត។ ការដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសក្នុងកម្មវិធីសិក្សានេះមិនមែនជាការចៃដន្យនោះទេគឺដោយសារតែមើលឃើញពីសារៈប្រយោជន៍និងភាពចាំបាច់របស់វា។ ទោះបីជាប្រវត្តិសាស្រ្តនៃការសិក្សាភាសាអង់គ្លេសត្រូវបានហាមឃាត់និងរើសអើងតាមសម័យកាលមួយចំនួនមែនប៉ុន្តែបន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ មកការសិក្សាភាសាអង់គ្លេសត្រូវបានលើកទឹកចិត្តក្នុងការសិក្សាសារជាថ្មីម្តងទៀតនៅក្នុងប្រទេសកម្ពុជា (Ravuth,២០១៩)។

ដើម្បីអោយការសិក្សាភាសាអង់គ្លេសនៅតាមសាលាសាធារណៈរបស់រដ្ឋមានការរីកចម្រើនជាលំដាប់ ថ្នាក់ដឹងនាំតែងតែខិតខំរិះរកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីអោយការអប់រំភាសាទីពីរមួយនេះមានប្រសិទ្ធភាពខ្ពស់ជាលំដាប់និងធ្វើការកែប្រែប្រវត្តិសាស្រ្តជូរចត់របស់វា។ សកម្មភាពទាំងនោះមានដូចជាការធ្វើកំណែទម្រង់កម្មវិធីសិក្សា ការពង្រឹងសមត្ថភាពគ្រូជាប្រចាំ ការផ្តល់អាហាររូបករណ៍ដល់បុគ្គលិកអប់រំដើម្បីជាការលើកទឹកចិត្តអោយពួកគាត់មានឪកាសបានពង្រីកចំណេះដឹងរបស់ខ្លួន ការផ្តល់ជាមេដាយលើកទឹកចិត្តដល់បុគ្គលិកដែលមានសមត្ថភាពនិងមានស្នាដៃក្នុងការបំពេញភារកិច្ចរបស់ខ្លួន ការធ្វើកំណែទម្រង់សៀវភៅសិក្សាគោលភាសាអង់គ្លេសដែលកន្លងមកយើងបានប្រើប្រាស់សៀវភៅសិក្សាគោល English For Cambodia(EFC)សម្រាប់ដំណើរការសិក្សាភាសាអង់គ្លេសដំបូងក្នុងកម្មវិធីសិក្សាភាសាអង់គ្លេសក្នុងសាលារដ្ឋអស់រយៈពេលជាច្រើនឆ្នាំបន្ទាប់មកក៏មានការផ្លាស់ប្តូរសៀវភៅសិក្សាសៀវភៅគោលថ្មីក្រោមជំនួយរបស់អង្គការ KIZUNA រួមជាមួយសកម្មភាពជាច្រើនទៀតដែលទាក់ទងជាមួយនិងការកែលម្អមុខវិជ្ជាភាសាអង់គ្លេស(ក្រសួងអប់រំ យុវជន និងកីឡា,២០១៥)។ កន្លងមកនេះយើងសង្កេតឃើញថាការបង្រៀននិងការរៀនលើមុខវិជ្ជាភាសាអង់គ្លេសមានជួបប្រទះនិងបញ្ហាមួយចំនួនដែលជាកត្តាធ្វើអោយមានការជះឥទ្ធិពលមិនល្អទៅដល់លទ្ធផលនៃការសិក្សារបស់សិស្ស។ សិស្សភាគ

ច្រើនមានចំណេះដឹងមិនសមស្របជាមួយកម្រិតថ្នាក់ដែលខ្លួនកំពុងសិក្សា និងមួយភាគធំទៀតមានកម្រិតនៃការយល់ដឹងតិចតួចបំផុត។ ដោយសារតែលទ្ធផលសិក្សាមានការស្រុតចុះដូចនេះហើយទើបធ្វើឱ្យសិស្សជួបប្រទះជាមួយនិងគុណវិបត្តិច្រើននៅពេលដែលបន្តការសិក្សាទៅថ្នាក់លើទៀត និងអាចប៉ះពាល់ដល់ប្រព័ន្ធអប់រំមួយចំណែកផងដែរ។

នៅក្នុងការសិក្សាស្រាវជ្រាវមួយនេះចង់ទទួលបានព័ត៌មានជាក់លាក់មួយពីការគ្រប់គ្រងរបស់នាយកសាលាដែលទាក់ទងជាមួយនិង សេចក្តីណែនាំអំពីការបង្រៀននិងការរៀនភាសាអង់គ្លេស ការប្រើប្រាស់សៀវភៅសិក្សាគោល ការអនុវត្តម៉ោងសិក្សាតាមកម្រិតថ្នាក់ សមត្ថភាពនិងទេពកោសល្យគ្រូបង្រៀនភាសាអង់គ្លេស កិច្ចតែងការបង្រៀននិងសម្ភារៈឧបទ្ទេសរបស់គ្រូបង្រៀន ការវាយតម្លៃលទ្ធផលសិក្សាភាសាអង់គ្លេសរបស់សិស្ស ការចុះអធិការកិច្ចលើដំណើរការបង្រៀនភាសាអង់គ្លេស និងដំណើរការសិក្សារបស់សិស្ស។ ម្យ៉ាងវិញទៀតការសិក្សាក៏ចង់ដឹងអំពីផលលំបាកក៏ដូចជាបញ្ហាប្រឈមនានាសម្រាប់នាយកសាលាដែលតែងតែកើតមានឡើងនិងក្លាយជាឧបសគ្គមួយដែលធ្វើអោយរាំងស្ទះនៅក្នុងដំណើរការគ្រប់គ្រងនេះផងដែរ។

សម្រាប់ដំណើរការនៃការសិក្សាស្រាវជ្រាវគឺយើងបានធ្វើឡើងចំពោះសាលាទាំង៨ ក្នុងស្រុកព្រៃកប្បាសដែលក្នុងនោះមានគណៈគ្រប់គ្រងសរុបចំនួន២២នាក់ ស្រី១នាក់ គ្រូបង្រៀនភាសាអង់គ្លេសចំនួន២១នាក់ ស្រី៣នាក់ និងសិស្សសរុបចំនួន១៦០នាក់ ស្រី៨០នាក់។ ការចុះប្រមូលយកព័ត៌មានគឺត្រូវបានធ្វើឡើងទៅកាលបរិច្ឆេទដែលបានកំណត់គឺនៅក្នុងចន្លោះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២ និងទៅតាមសាលាគោដៅនីមួយៗ។ ការសិក្សាស្រាវជ្រាវត្រូវបានធ្វើឡើងតាមបែបបរិមាណវិស័យ។ រាល់ទិន្នន័យដែលប្រមូលបានត្រូវបានយកមកវិភាគតាមកម្មវិធី Microsoft Excel និងធ្វើការសង់ជា Column Chart និងរកជាភាគរយ។

ការសិក្សាស្រាវជ្រាវនេះបានរកឃើញថាការគ្រប់គ្រងរបស់នាយកសាលាគឺនៅមានចំណុចខ្វះខាតក្នុងការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេស។ ដែលចំណុចទាំងនោះរួមមានដូចជាៈ សៀវភៅសិក្សាគោល សមត្ថភាពនិងទេពកោសល្យរបស់គ្រូ កិច្ចតែងការនិងសម្ភារៈឧបទ្ទេស ការចុះអធិការកិច្ច

និងការសិក្សារបស់សិស្ស។ លើសពីនេះក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលពាក់ព័ន្ធទៅនិងកត្តាផ្សេងៗ ដូចជា កត្តាសាលារៀន កត្តាគ្រូបង្រៀន កត្តាសិស្សនិង កត្តាមជ្ឈដ្ឋានជុំវិញ។

លទ្ធផលដែលទទួលបានពីការសិក្សាស្រាវជ្រាវនិងរួមចំណែកយ៉ាងសំខាន់ក្នុងការចូលរួមជួយស្វែងរកនិងកំណត់បានគោលដៅជាក់លាក់ណាមួយពីបញ្ហាប្រឈមដើម្បីស្វែងរកដំណោះស្រាយល្អៗក្នុងការកែលម្អក៏ដូចជាបំពេញបន្ថែមនូវចន្លោះខ្វះខាតដែលកើតមានឡើងនៅក្នុងការគ្រប់គ្រងនាពេលបច្ចុប្បន្នរបស់នាយកសាលា។

# Abstract

English is an important subject and a second language that is included in the state curriculum as well as other subjects for the main purpose of contributing to the improvement of the quality of language education. More, the inclusion of English subjects in this curriculum is not accidental; it is due to its importance and necessity. Although the history of English language learning has been banned and discriminated against over time, after the 1993 elections, English language learning was encouraged again in Cambodia.

In order for English language education in public schools to grow steadily, the leadership is constantly working to find ways to make this second language education more effective and to change its bitter history. These activities include curriculum reform, regular teacher capacity building, providing scholarships to educators to encourage them to expand their knowledge, and awarding medals to competent staff. In the past, we have used the English for Cambodia ( EFC ) textbook for the first English language learning process in the public school English curriculum for a period of time. Years later, there were also changes to textbooks, new textbooks, with the help of KIZUNA, along with many other activities related to the improvement of English language subjects.

In the past, we have observed that teaching and learning in English has encountered a number of problems that have a negative impact on student learning outcomes. Most students have knowledge that is not commensurate with the grade level they are studying and a large part has very little level of understanding. Due to the drop in academic results, students face many disadvantages when pursuing higher education and may even affect the education system.

In this study, we would like to obtain specific information from the management of the principal related to the instruction on teaching and learning English, the use of textbooks, the implementation of study hours by grade level, competency and teacher talent. English Lesson Plans and Teacher Instructional Materials, Assessment of English Learning Outcomes, Inspection of English Teaching Process and Student Learning Process. On the other hand, the study also wants to know the difficulties as well as the challenges for principals that often occur and become an obstacle in the management process.

For the research process, we conducted 8 schools in Prey Kabbas district, including a total of 22 management, 1 female, 21 English teachers, 3 females and a total of 160 students, 80 females. The data collection was conducted on a set date, between May 2, 2022 and July 30, 2022, and at each target school. The research was conducted in a quantitative manner. All data collected is analyzed in Microsoft Excel and constructed as a Column Chart and found as a percentage.

The study found that principals' management is still lacking in teaching and learning English. These include: textbooks, teachers' competencies and talents, lesson plans and materials, assessment of student learning outcomes, inspections and student learning. In addition, there are a number of challenges related to other factors such as school factors, teachers, students and the environment.

The results of the research and contribute significantly to help find and identify specific goals from the challenge to find better solutions to improve as well as fill the gaps that occur in The current management of the principal.

# ជំពូក១
# សេចក្ដីផ្ដើម

# ជំពូក១៖ សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការសិក្សាអប់រំគឺជារបៀបមួយសំរាប់ផ្តល់នូវតម្រិះវិជ្ជានិងប្រពៃណីទំនៀមទំលាប់សម្រាប់មនុស្ស នៅក្នុងសង្គមមួយឬប្រទេសមួយ។ ការចាត់ចែងដើម្បីបង្កើតអោយមានការបណ្តុះបណ្តាលនិងបង្រៀនទៅដល់លើបណ្តាអ្នករៀនទាំងឡាយណាដែលព្រមទទួលយកការអប់រំនេះ។ ការសិក្សាអប់រំបានផ្តោតទៅលើច្រើនមុខជំនាញជាច្រើនទៀតដូចជា ចិត្តវិទ្យា, ទស្សនវិទ្យា, សង្គមវិទ្យា, វិទ្យាសាស្រ្តនយោបាយ,អក្សរសាស្រ្ត, នរវិទ្យា, ជាតិពន្ធុវិទ្យា, ជាតិពន្ធុសាស្រ្ត, លេខនព្វន្ត, ភាសាបរទេសរួមជាមួយនិងមុខជំនាញផ្សេងៗជាច្រើនបន្ថែមទៀតដែលត្រូវបានបង្រៀននៅតាមសាលារៀន(ក្រសួងអប់រំយុវជននិងកីឡា,២០១៩) ។

ការព្រមទទួលយកការអប់រំគឺជាកាតព្វកិច្ចមួយយ៉ាងសំខាន់ដែលប្រជាជនគ្រប់រូបនៅគ្រប់បណ្តាប្រទេសទាំងអស់ដែលស្ថិតនៅលើសកលលោកត្រូវតែធ្វើការអនុវត្តនៅពេលដែលពួកគេជំពេញវ័យត្រូវចូលសិក្សា។ មនុស្សដែលទទួលបានការអប់រំត្រឹមត្រូវនឹងក្លាយជាមនុស្សដែលមានសមត្ថភាពពេញលេញដែលអាចជួយអោយជីវិតរបស់ពួកគេព្រមទាំងក្រុមគ្រួសារមានភាពស្រស់បំព្រងនិងល្អប្រសើរចាកឆ្ងាយចេញពីភាពល្ងង់ខ្លៅ។ លើសពីនេះទៅទៀតពួកគេអាចប្រើសមត្ថភាពរបស់ពួកគេសំរាប់ជួយកសាងប្រទេសជាតិរបស់ខ្លួនអោយមានភាពរីកចម្រើននិងរុងរឿងទៀតផង។ ប្រទេសណាដែលមានប្រជាជនទទួលបានការអប់រំបានល្អគឺជាប្រទេសដែលមានធនធានមនុស្សគ្រប់គ្រាន់សំរាប់ជួយជ្រោមជ្រែងប្រទេសជាតិរបស់ខ្លួនអោយរីកចម្រើនឈានទៅមុខនិងបន្តកសាងជាតិពីមួយជំនាន់ទៅមួយជំនាន់ជារាងរហូត។ ហេតុដូចនេះហើយបានជាបណ្តាប្រទេសទាំងអស់លើសកលលោកខិតខំយកចិត្តទុកដាក់ជាខ្លាំងទៅលើប្រព័ន្ធអប់រំ ដោយរៀបចំអោយមានជាប្រព័ន្ធតាំងពីថ្នាក់ក្រសួង មន្ទីរ ស្រុក រហូតដល់សាលារៀន និងគ្រូបង្រៀនទៀតផង ក្នុងគោលបំណងចង់អោយការអប់រំនៅក្នុងប្រទេសរបស់ខ្លួនមានភាពរីកចម្រើន។ (Ministry Of Education, Youth and Sport.(February, 2001). Pre-Service Training

Programme for Lower Secondary School Teachers of English, Methodology, an introduction to methodology).

នៅក្នុងខែកញ្ញា ឆ្នាំ ២០១៥ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តនូវរបៀបវារៈឆ្នាំ ២០៣០ ថ្មី សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ដែលត្រូវបានគេស្គាល់ថា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ ដោយមានគោលបំណងដើម្បីនាំទៅរកសកម្មភាពនៅក្នុងផ្នែកដ៏សំខាន់ៗ នាឆ្នាំ ២០៣០។ គោលដៅទាំងនេះត្រូវបានចែកចេញជា ១៦៩ ចំណុចដៅ និង ២៣០ សូចនាករ។ គោលដៅទាំងនេះមានចំនួន ១៧ ចំណុចសំខាន់សំខាន់ៗ(អង្គការទិន្នន័យអំពីការអភិវឌ្ឍ,២០១៥)។ នៅក្នុងនេះយើងឃើញថាចំនុចទី៤ដែលផ្តោតទៅលើការអប់រំដែលស្របទៅនិងគោលនយោបាយទាំងពីររបស់រាជរដ្ឋាភិបាលកម្ពុជាមានជាអាទិ៍៖ **គោលនយោបាយទី១៖** ធានាអោយការអប់រំមានគុណភាពខ្ពស់ប្រកបដោយសមធម៌ បរិយាបណ្ន និងលើកកម្ពស់ឳកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ **គោលនយោបាយទី២៖** ធានាភាពស័ក្តសិទ្ធិនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់សំដាប់ថ្នាក់(ក្រសួងអប់រំយុវជននិងកីឡា,២០១៨)។ នៅក្នុងនេះផងដែរកម្ពុជាបានធ្វើការផ្លាស់ប្តូរគោលដៅចាស់របស់ខ្លួនដែលមានឈ្មោះថា«គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍»ដែលបានចាប់ផ្តើមនៅឆ្នាំ២០០២និងបានផុតកំណត់នៅចុងឆ្នាំ២០១៥ និងជំនួយសមកវិញនូវគោលដៅថ្មីមួយដែលត្រូវបានគេស្គាល់ថា «គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤»ដែលហៅកាត់ថា(SDG4) និងធ្វើការអនុវត្តចាប់ពីឆ្នាំ២០១៥ ទៅដល់ឆ្នាំ ២០៣០(អង្គការទិន្នន័យអំពីការអភិវឌ្ឍ,២០១៥)។

លើសពីនេះទៅទៀតស្ថិតក្នុងបរិបទថ្មីនៃការវិវឌ្ឍរបស់ពិភពលោកសំរាប់កម្ពុជាក៏កាន់តែយកចិត្តទុកដាក់ជាខ្លាំងទៅលើវិស័យអប់រំពីសំណាក់រាជរដ្ឋាភិបាលនិង ថ្នាក់ដឹកនាំដែលពាក់ព័ន្ធផងដែរ ដោយបានរៀបចំកែរលម្អតាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោមដើម្បីអោយប្រព័ន្ធអប់រំនៅក្នុងប្រទេសរបស់ខ្លួនមានភាពរីកចម្រើន។ ពីមួយឆ្នាំទៅមួយឆ្នាំក្រសួងអប់រំបានខិតខំប្រឹងប្រែងរិះរកគ្រប់វិធីសាស្ត្រនិងមធ្យោបាយជាច្រើនថែមទាំងបានដាក់ចេញនូវគោលនយោបាយអប់រំជាបន្តបន្ទាប់ក្នុងគោលបំណងលៃ

យ៉ាងណាអោយការអប់រំមានការរីកចម្រើនដូចប្រទេសអភិវឌ្ឍន៍មួយចំនួនទៀតដែរ និងដើម្បីប្រកួតប្រជែងចំណេះដឹងក្នុងវិស័យអប់រំជាមួយបណ្តាប្រទេសជិតខាងផងដែរ។

ជាក់ស្តែងផ្អែកទៅលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់កន្លងមកនេះ ក្រសួងអប់រំ យុវជន និងកីឡា បន្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាទាំង ១៥ ណុច ដោយឈរលើមូលដ្ឋានសសរស្តម្ភ ទាំង ៥ ដែលមានដូចជា៖ **សសរស្តម្ភទី១៖** ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន។ **សសរស្តម្ភទី២៖** ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អបរិស្ថានសិក្សា។ **សសរស្តម្ភទី៣៖** ការដាក់ឱ្យអនុវត្តអធិការកិច្ច។ **សសរស្តម្ភទី៤៖** ការពង្រឹងវង្វាយតម្លៃសិក្សាដូចជាការប្រឡង វង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។ **សសរស្តម្ភទី៥៖** ការកែទម្រង់ឧត្តមសិក្សា។ ចំពោះកំណែទម្រង់ទាំង១៥ចំណុចមានដូចជា៖ ១.ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២.ការពង្រាយគ្រូបង្រៀន ៣.កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន ៤.ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ៥. ការងារអធិការកិច្ច ៦.វង្វាយតម្លៃលទ្ធផលសិក្សា ៧.កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ ៨.កំណែទម្រង់កម្មវិធីសិក្សានិងសៀវភៅសិក្សាគោល ៩.ការសាងសង់អគារសិក្សានិងការជួសជុល ១០.ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា ១១.ការលើកកម្ពស់វិស័យកីឡា ១២.ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន ១៣.ការអប់រំបច្ចេកទេស ១៤.ការបង្កើតសាលារៀនជំនាន់ថ្មី ១៥.ការរៀបចំគន្លងអាជីព និងការបណ្តុះបណ្តាលនាយកសាលា(ក្រសួងអប់រំយុវជននិងកីឡា ,២០១៨)។ សំរាប់មុខវិជ្ជាសិក្សានៅក្នុងកម្មវិធីសិក្សាគឺមានមុខវិជ្ជាជាច្រើនដែលត្រូវបានដាក់បញ្ចូលនៅក្នុងនោះយើងឃើញថាចំពោះមុខវិជ្ជាភាសាបរទេសវិញ ក្រសួងបានជ្រើសរើសយកភាសាអង់គ្លេសដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាថ្នាក់ទី៧ចាប់ពីឆ្នាំ២០០២និងថ្នាក់បន្តបន្ទាប់ជារាងរាល់ឆ្នាំរហូតដល់ថ្នាក់ទី១២ និង ថ្នាក់សកលវិទ្យាល័យ។ ព្រោះភាសាអង់គ្លេសជាភាសាមួយដែលពេញនិយមនិងមានការប្រើប្រាស់ច្រើនជាងគេស្ទើតែគ្រប់ប្រទេសក្នុងការទាំនាក់ទំនង(Ravuth,២០១៩)។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ភាសាអង់គ្លេសក៏ត្រូវបានដាក់បញ្ចូលផងដែរនៅក្នុងកម្មវិធីសិក្សាសំរាប់កម្រិតបឋមសិក្សាគឺចាប់ពីថ្នាក់ទី៤ដល់ថ្នាក់ទី៦ ដែលក្នុងមួយសប្តាហ៍មាន២ម៉ោងហើយក្នុង១ម៉ោងមាន៤០នាទី ដើម្បីអោ

យសិស្សមានមូលដ្ឋានគ្រឹះភាសាអង់គ្លេសសំរាប់ជាដើមទុនសំរាប់សិក្សានៅកម្រិតមធ្យមសិក្សា(ក្រសួងអប់រំយុវជននិងកីឡា,២០១៤)។ លើសពីនេះទៅទៀតក្រសួងបានសហការជាមួយអង្គការជាដៃគូរគឺអង្គការ«KIZUNA» របស់ប្រទេសជប៉ុនដើម្បីធ្វើការកែលម្អកម្មវិធីសិក្សាក៏ដូចជាសៀវភៅសិក្សាគោលអោយការសិក្សាភាសាអង់គ្លេសមានភាពប្រសើរឡើង និង ត្រឹមត្រូវតាមស្តង់ដារអន្តរជាតិ(ក្រសួងអប់រំយុវជននិងកីឡា,២០០១)។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

បើទោះបីជាការសិក្សាភាសាអង់គ្លេសត្រូវបានយកចិត្តទុកដាក់យ៉ាងជិតដល់ពីសំណាក់ក្រសួងអប់រំ យុវជន និងកីឡា ទាំងការរៀបចំកម្មវិធីសិក្សា ការកែប្រែសៀវភៅសិក្សាគោល ការផ្គត់ផ្គង់សៀវភៅសិក្សាគោលទៅតាមសាលារៀន ការផ្គត់ផ្គង់សៀវភៅសំរាប់ណែនាំគ្រូ ការធ្វើសិក្ខាសាលា និងសម្ភារផ្សេងៗមួយចំនួនទៀតជាច្រើន បូករួមជាមួយនិងការខិតខំប្រឹងប្រែងបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ពីសំណាក់លោកគ្រូអ្នកគ្រូយ៉ាងណាក៏ដោយក៏លទ្ធផលនៃការសិក្សាភាសាអង់គ្លេសរបស់សិស្សពុំទាន់ទទួលបានលទ្ធផលល្អដូចការរំពឹងទុកនៅឡើងទេ ជាក់ស្តែងសំរាប់វិទ្យាល័យក្នុងស្រុកព្រៃកប្បាសខេត្តតាកែវនេះវិញ យើងសង្កេតឃើញថាមានសិស្សជាច្រើនដែលបានកំពុងសិក្សានៅថ្នាក់វិទ្យាល័យនិងខ្លះទៀតបានបញ្ចប់ថ្នាក់វិទ្យាល័យហើយនៅពុំទាន់អាចសរសេរ ស្តាប់ និយាយ និងអានបាននៅឡើយទេ។ ចំពោះសិស្សដែលអាចយកភាសាអង់គ្លេសទៅប្រើប្រាស់បានមានចំនួនតិចតួចណាស់។ ហើយម្យ៉ាងទៀតសិស្សភាគច្រើនអាចត្រឹមតែអានអក្សរបានពី៤ទៅ១០ពាក្យតែប៉ុណ្ណោះ។ ហេតុដូចនេះហើយទើបបណ្តាលអោយអ្នកសិក្សាស្រាវជ្រាវបានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយគឺ«**ការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យៈករណីសិក្សាស្រុកព្រៃកប្បាសខេត្តតាកែវ។**» មកធ្វើការសិក្សាស្រាវជ្រាវទុកជាជំនួយស្មារតីទៅ ដល់នាយកសាលា ឱ្យមានការទទួលខុសត្រូវ និងយកចិត្តទុកដាក់បន្ថែមចំពោះអង្គភាពរបស់ខ្លួនក្នុងការអនុវត្តភារកិច្ចក្នុងការគ្រប់គ្រងដល់ការបង្រៀននិងរៀន

ភាសាអង់គ្លេសអោយមានប្រសិទ្ធភាពឡើងវិញ និងស្វែងរកដើមចមដែលបណ្តាលឱ្យមានបញ្ហាប្រឈមទាំងឡាយក្នុងការអនុវត្តប្រែក្លាយជាដំណោះស្រាយដ៏មានប្រសិទ្ធភាព។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការលើកយកប្រធានបទខាងលើនេះមកធ្វើការសិក្សាស្រាវជ្រាវមានគោលបំណងចំនួនពីរគឺ៖

១.រកឱ្យឃើញពីការស្ថានភាពនៃការគ្រប់គ្រងក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យក្នុងស្រុកព្រៃកប្បាសខេត្តតាកែវ។

២.កំណត់បានពីបញ្ហាប្រឈមនានាដែលជះឥទ្ធិពលដល់ការគ្រប់គ្រងក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យ។

## ១.៤. សំណួរសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវខាងលើ យើងមានសំណួរស្រាវជ្រាវចំនួនពីរដូចខាងក្រោមគឺ៖

១.តើស្ថានភាពនៃការគ្រប់គ្រងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យមានលក្ខណៈដូចម្តេចខ្លះ?

២.តើមានបញ្ហាប្រឈមអ្វីខ្លះដែលជះឥទ្ធិពលដល់ការគ្រប់គ្រងក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះនឹងបានផ្តល់សារៈសំខាន់ ជាច្រើនទៅដល់វិស័យអប់រំជាពិសេសបានគាំទ្រទៅដល់ការធ្វើកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ស្របទៅតាមយុទ្ធសាស្ត្រនិងកំណែទម្រង់ថ្មី។ លើសពីនេះទៅទៀតតាមរយៈការសិក្សាស្រាវជ្រាវនេះ និងបានចូលរួមចំណែកនៅក្នុងការកំណត់បាននូវបញ្ហាជាក់លាក់ ដើម្បីធ្វើការកែលម្អទៅដល់ការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេស

នៅក្នុងស្រុកព្រៃកប្បាសអោយមានភាពប្រសើរឡើងវិញ។ ថែមទាំងបានផ្តល់នូវចំណេះដឹង និងបទពិសោធន៍ល្អៗ ដល់អ្នកសិក្សាស្រាវជ្រាវនានាដែលមានបំណងចង់សិក្សាជាបន្តបន្ទាប់ទៀតដែលពាក់ព័ន្ធទៅនឹងប្រធានបទខាងលើ។ ម្យ៉ាងទៀតវាបានផ្តល់ឱកាស ដល់នាយកសាលា លោកគ្រូ អ្នកគ្រូ ក្នុងការចូលរួមកែលម្អការងារ របស់ខ្លួនពាក់ព័ន្ធនឹងការគ្រប់គ្រង ការបង្រៀននិងរៀន រដ្ឋបាលថ្នាក់ រដ្ឋបាលគ្រូ ព្រមទាំង បង្កើនទំនាក់ទំនងល្អរវាងគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀន គ្រូបង្រៀននិងគ្រូបង្រៀន គ្រូបង្រៀននិងសិស្សានុសិស្ស សាលារៀន និងសហគមន៍ជាដើម។ តាមរយៈប្រធានបទនេះក៏ជាផែនទីនិងជាសូចនាករមួយក្នុងការជំរុញឱ្យ នាយកសាលា គ្រូបង្រៀន អាចមានឱកាសទទួលបានស្នាដៃ ជាសាលាស្អាត នាយកល្អ គ្រូល្អ គ្រូឆ្នើមជាដើម(ក្រសួងអប់រំយុវជននិងកីឡា,២០១៨)។

## ១.៦. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទ « **ការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យ៖ករណីសិក្សាស្រុកព្រៃកប្បាសខេត្តតាកែវ** » ធ្វើឡើងដោយផ្តោតទៅលើវិទ្យាល័យទាំងអស់ចំនួន០៨ដែលមាននៅក្នុងស្រុកព្រៃកប្បាសខេត្តតាកែវ ដែលមានដូចជា៖ ១.វិទ្យាល័យសមរលាវ ២.វិទ្យាល័យចំប៉ា ៣.វិទ្យាល័យកំពែង ៤.វិទ្យាល័យក្បឺមាស ៥.វិទ្យាល័យហេងសំរិន ព្រៃល្វា ៦.វិទ្យាល័យអង្គរអណ្តែត ៧.វិទ្យាល័យក្រាំងស្លា ៨.វិទ្យាល័យបានយ។

## ១.៧. រចនាសម្ព័ន្ធស្រាវជ្រាវ

ក្នុងអត្ថបទស្រាវជ្រាវនេះ មានប្រាំជំពូក ហើយក្នុងជំពូកនីមួយៗមានដូចជា៖

**ជំពូក១** លើកឡើងពី សេចក្តីផ្តើមនៃការស្រាវជ្រាវ រួមមាន៖ លំនាំបញ្ហា ចំណោទបញ្ហា គោលបំណង សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធ ។

**ជំពូក២** លើកឡើងពី ការរំឭកទ្រឹស្តី ដែលក្នុងនោះរួមមានៈ ការសិក្សាពាក្យការសិក្សាពាក្យគន្លឹះ ការងារគ្រប់គ្រង ការអប់រំភាសាអង់គ្លេសនៅកម្ពុជា គោលបំណងនៃការសិក្សាភាសាអង់គ្លេស របាយម៉ោងសិក្សា ការអនុវត្តការបង្រៀននិងរៀន ការវាយតម្លៃ និង កម្មវិធីសិក្សា។

**ជំពូក៣** លើកឡើងពី វិធីសាស្ត្រនៃការស្រាវជ្រាវ ដែលក្នុងនោះរួមមានៈ គម្រោងវិភាគ ការប្រមូលទិន្នន័យ ឧបករណ៍ស្រាវជ្រាវ ការជ្រើសរើសភាគសំណាក និងការវិភាគទិន្នន័យ។

**ជំពូក៤** លើកឡើងពី លទ្ធផលនៃការស្រាវជ្រាវ រួមមានៈ ឧបករណ៍វិភាគទិន្នន័យ ដំណាក់កាលនៃការវិភាគទិន្នន័យ ការវិភាគទិន្នន័យតាមកម្រងសំណួរជាបន្តបន្ទាប់។

**ជំពូក៥** លើកឡើងពី សេចក្តីសន្និដ្ឋាន និងសំណូមពរ ដែលក្នុងជំពូកចុងក្រោយនេះ យើងនឹងបង្ហាញពីអ្វីដែលបានរកឃើញទាក់ទងនឹងការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេស បញ្ហាប្រឈម និងការលើកឡើងជាទស្សនទានដល់ ភាគីពាក់ព័ន្ធ នៅក្នុងការគ្រប់គ្រងការបង្រៀននិងរៀន ព្រមទាំងសំណូមពរមួយចំនួន ដើម្បីធ្វើឱ្យការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេសកាន់តែមានភាពប្រសើរឡើងនិងប្រកប ដោយប្រសិទ្ធភាពខ្ពស់។

## ១.៨. កាលបរិច្ឆេទនៃការស្រាវជ្រាវ

តារាងទី1៖កាលបរិច្ឆេទនៃការស្រាវជ្រាវ

| ល.រ | ចំណងជើង | កាលបរិច្ឆេទ |
|---|---|---|
| ១ | ការពារប្រធានសំណើរប្រធានបទស្រាវជ្រាវ | ១៥ មករា ២០២២ |
| ២ | សេចក្តីផ្តើម | ០៧ ឧសភា ២០២២ |
| ៣ | រំលឹកទ្រឹស្តី | ២១ ឧសភា ២០២២ |
| ៤ | វិធីសាស្រ្តស្រាវជ្រាវនិងការប្រមូលទិន្នន័យ | ឧសភា ដល់ កក្កដា ២០២២ |
| ៥ | វិភាគស៊ីជម្រៅលើលទ្ធផលរបកគំហើញនិងការពិភាក្សា | ១៧ សីហា ២០២២ |
| ៦ | សេចក្តីសន្និដ្ឋាន និងសំណូមពរ | ២៤ សីហា ២០២២ |
| ៧ | ការពារនិក្ខេបបទសាកល្បង | ០១ ដល់ ០២ តុលា ២០២២ |
| ៨ | ការទទួលនិក្ខេបបទ សម្រាប់ការពារបញ្ចប់ | ០៣ ដល់ ០៨ តុលា ២០២២ |
| ៩ | ការការពារនិក្ខេបបទបញ្ចប់វគ្គសិក្សា | ០៥ ដល់ ០៦ វិច្ឆិកា ២០២២ (៧:៣០ ដល់ ១៧:00) |
| ១០ | ប្រគល់និក្ខេបបទចុងក្រោយបន្ទាប់ពីការពារបញ្ចប់ដោយជោគជ័យ | ២៦ ដល់ ៣០ វិច្ឆិកា ២០២២ |

(វិទ្យាស្ថានជាតិអប់រំ,២០២២)

# ជំពូក២
# រំលឹកទ្រឹស្តី

# ជំពូក២៖ រំលឹកទ្រឹស្តី

នៅក្នុងជំពូកមួយនេះការសិក្សាស្រាវជ្រាវគឺត្រូវបានពិភាក្សាផ្តោតទៅលើការគ្រប់គ្រងជាពិសេសសំរាប់ការបង្រៀននិងរៀនភាសាអង់គ្លេសដែលស្ថិតនៅកម្រិតវិទ្យាល័យគឺថ្នាក់ទី១០ ទី១១ និងទី១២។ ហើយការពិភាក្សាគឺត្រូវបានលើកយកចំណុចសំខាន់ៗ ដែលទាក់ទងជាមួយប្រធានបទរួមមាន៖ ការសិក្សាពាក្យគន្លឹះ ការងារគ្រប់គ្រង ការអប់រំភាសាអង់គ្លេសនៅកម្ពុជា គោលបំណងនៃការសិក្សាភាសាអង់គ្លេស របាយម៉ោងសិក្សា ការអនុវត្តការបង្រៀននិងរៀន ការវាយតម្លៃ និង កម្មវិធីសិក្សា។

## ២.១. ការសិក្សាពាក្យគន្លឹះ

ដើម្បីឱ្យកាន់តែមានភាពច្បាស់លាស់និងលម្អិតថែមទៀតនៅក្នុងការសិក្សាស្រាវជ្រាវដែលទាក់ទងនឹងប្រធានបទនិក្ខេបបទមួយនេះ យើងគួរគម្បីស្គាល់ពីពាក្យគន្លឹះមួយចំនួនដូចជា៖

**ការគ្រប់គ្រង** បានន័យថា៖ ការបីបាច់, ការរក្សា, ការថែទាំដោយទទួលរងបន្ទុក រងខុសត្រូវលើខ្លួន។ ឧទាហរណ៍៖ការគ្រប់គ្រងសាលារៀន, ការគ្រប់គ្រងគ្រួសារ។ (វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨)។

**ការបង្រៀន**បានន័យថា៖ ការញុំាងអ្នកដទៃឱ្យរៀន, ការប្រៀនឱ្យចេះ, ការឱ្យចំណេះដោយការបង្ហាត់, បង្ហាញឱ្យចេះ។ឧទាហរណ៍៖ការបង្រៀនអក្សរ, ការបង្រៀនលេខ, ការបង្រៀនច្បាប់ ។ (វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ,២០០៨)។

**ការរៀន** បានន័យថា៖ ការសិក្សា, ការខំសង្កេតឱ្យចេះ, ការទទួលយកចំណេះ; ការហាត់, ការហ្វឹក : ការរៀនអក្សរ, ការរៀនចំណេះ, ការរៀនធ្វើការ ។ ការរៀនសូត្រ ឬ ការសូត្ររៀន ការរៀនដោយទន្ទេញដោយស្វាធ្យាយឱ្យចងចាំ ។ល។ (វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ,២០០៨)។

**ភាសាអង់គ្លេស** ៖ គឺជាភាសាអាល្លឺម៉ង់ប៉ែកខាងលិចនៃគ្រួសារភាសាឥណ្ឌូ - អឺរ៉ុប ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយភាសា ហ្វ្រីសៀន អាឡឺម៉ង់ និងហូឡង់ (ជាភាសាបែលហ្សិកហៅថា ហ្វ្លេមីស) ។ ភាសាអង់គ្លេសមានដើមកំណើតនៅប្រទេសអង់គ្លេស ហើយជាភាសាលេចធ្លោរបស់សហរដ្ឋអាមេរិក

ចក្រភពអង់គ្លេស កាណាដា អូស្ត្រាលី អៀរឡង់ នូវែលសេឡង់ និងប្រទេសកោះផ្សេងៗនៅសមុទ្រការាបៀន និងមហាសមុទ្រប៉ាស៊ីហ្វិក។ វាក៏ជាភាសាផ្លូវការរបស់ប្រទេសឥណ្ឌា ហ្វីលីពីន សិង្ហបុរី និងប្រទេសជាច្រើននៅអនុតំបន់សាហារ៉ាអាហ្វ្រិក រួមទាំងអាហ្វ្រិកខាងត្បូងផងដែរ។ ភាសាអង់គ្លេសគឺជាជម្រើសដំបូងនៃភាសាបរទេសនៅក្នុងប្រទេសភាគច្រើននៃពិភពលោក ហើយវាជាឋានៈដែលបានផ្តល់ឱ្យវានូវទីតាំងនៃភាសាសកល។ គេប៉ាន់ប្រមាណថាប្រហែលមួយភាគបីនៃចំនួនប្រជាជនពិភពលោក ប្រហែលជាពីរពាន់លាននាក់ឥឡូវនេះប្រើប្រាស់ភាសាអង់គ្លេស( David Crystal,២០២២ )។

**វិទ្យាល័យ** បានន័យថាៈជាកម្រិតថ្នាក់ពីថ្នាក់ទី១០ដល់ថ្នាក់ទី១២ ដែលយើងអាចហៅឈ្មោះម្យ៉ាងទៀតថាមធ្យមសិក្សាទុតិយមភូមិ។ នៅពេលដែលសិស្សានុសិស្សបញ្ចប់ការសិក្សាកម្រិតនេះគឺត្រូវធ្វើការឆ្លងកាត់ការប្រឡងសញ្ញាបត្រទុតិយភូមិឬយើងហៅខ្លីថា«ប្រលងបាក់ឌុប»។( ក្រសួងអប់រំ យុវជន និងកីឡា,២០១៥ )។

## ២.២. ការងារគ្រប់គ្រងអប់រំ

ការគ្រប់គ្រងការអប់រំ សំដៅលើកិច្ចការងារណាដែលទាក់ទងជាមួយនិងការគ្រប់គ្រងប្រព័ន្ធអប់រំ ដែលវាអាចកើតឡើងទៅបានដោយសារសកម្មភាពនៃមនុស្សមួយក្រុមរួមបញ្ចូលគ្នានូវធនធានសមត្ថភាព ចំណេះដឹង ទេពកោលសល្យ និងសម្ភារៈ ដើម្បីធ្វើការត្រួតពិនិត្យ រៀបចំផែនការ បង្កើតយុទ្ធសាស្ត្រ និងអនុវត្តទៅតាមរចនាសម្ព័ន្ធដើម្បីប្រតិបត្តិប្រព័ន្ធអប់រំមួយ។ ការអប់រំគឺជាការផ្ទេរនូវចំណេះដឹង ជំនាញ គុណតម្លៃ ជំនឿ ទម្លាប់ និងអាកប្បកិរិយា ជាមួយនឹងបទពិសោធន៍សិក្សា។ ប្រព័ន្ធអប់រំគឺជាប្រព័ន្ធអេកូឡូស៊ី នៃអ្នកជំនាញក្នុងស្ថាប័នអប់រំ ដូចជាក្រសួងរដ្ឋាភិបាល សហជីព ក្រុមប្រឹក្សាច្បាប់ ទីភ្នាក់ងារ និងសាលារៀន។ ប្រព័ន្ធអប់រំមានប្រធានផ្នែកនយោបាយ នាយកសាលា បុគ្គលិកបង្រៀន បុគ្គលិកមិនបង្រៀន បុគ្គលិករដ្ឋបាល និងអ្នកជំនាញផ្នែកអប់រំផ្សេងទៀត ដែលធ្វើការរួមគ្នាដើម្បីពង្រឹង និងលើកកម្ពស់ នៅគ្រប់កម្រិតនៃប្រព័ន្ធអេកូអប់រំ។ ការគ្រប់គ្រងត្រូវបានទាមទារឱ្យមានការគ្រប់គ្រងពាក់ព័ន្ធនឹង

ការធ្វើផែនការ ការរៀបចំ ការអនុវត្ត ការពិនិត្យឡើងវិញ ការវាយតម្លៃ និងការរួមបញ្ចូលនៃស្ថាប័នមួយ (ក្រសួងអប់រំ យុវជន និងកីឡា,២០១៦)។

### ២.២.១. អត្ថន័យនៃការគ្រប់គ្រង

ការងារគ្រប់គ្រងគឺមានន័យសំដៅទៅលើការធ្វើផែនការ ការរៀបចំផែនការអោយបានត្រឹមត្រូវ ការរៀបចំចាត់ចែងទៅតាមផ្នែក ការដឹកនាំតាមផែនការ រួមជាមួយនិងការត្រួតត្រាពិនិត្យធនធានមនុស្សនិងធនធានដទៃទៀតដែលមានជាប់ទាក់ទង ដើម្បីសម្រេចគោលដៅរបស់អង្គភាព ឬស្ថាប័នរបស់ខ្លួនអោយដំណើរការប្រកបដោយប្រសិទ្ធភាពខ្ពស់។ ឬក៏អាចនិយាយបានថាជាការធ្វើឱ្យសម្រេចគោលដៅប្រកបដោយប្រសិទ្ធភាព ដោយមានការចូលរួមសហការគ្នាជាមួយបុគ្គលិកគ្រប់ផ្នែក តាមរយៈ ការធ្វើផែនការ ការរៀបចំចាត់ចែងអនុវត្ត ការដឹកនាំ និងការត្រួតពិនិត្យធនធានរបស់អង្គភាព(ក្រសួងអប់រំ យុវជន និងកីឡា,២០១៦)។

### ២.២.២. ឋានានុក្រមនៃការគ្រប់គ្រង

ជាទូទៅសំរាប់ការគ្រប់គ្រងត្រូវបានចែកចេញជាឋានានុក្រមដែលមានបីកម្រិតគឺ ១.ការគ្រប់គ្រងថ្នាក់លើ(top management) គឺជាការទទួលខុសត្រូវរាល់កិច្ចការប្រតិបត្តិការទាំងអស់ដែលមាននៅក្នុងអង្គភាពទាំងមូលជារួមមានដូចជា៖ ការផ្តួចផ្តើមគំនិត បង្កើតយុទ្ធសាស្រ្ត ចក្ខុវិស័យ វប្បធម៌ជំរុញលើកទឹកចិត្តបុគ្គលិកក្នុងអង្គភាព។ ២.ការគ្រប់គ្រងថ្នាក់កណ្តាល(Middle management) គឺជាការទទួលខុសត្រូវចំពោះការអនុវត្តផែនការដែលបានបង្កើតឡើងរួចរាល់ហើយ ការប្រើប្រាស់យុទ្ធសាស្រ្ត គោលនយោបាយ និងការណែនាំការប្រតិបត្តិតាមផ្នែករបស់ខ្លួន។ ៣.ការគ្រប់គ្រោងថ្នាក់ក្រោម(First-line management) គឺការដឹកនាំធ្វើសកម្មភាពរបស់បុគ្គលិកដើម្បីប្រតិបត្តិទៅតាមផែនការដែលបានដាក់ចុះនោះ។ ៤.ការប្រតិបត្តិ(Operating Employees) គឺជាការទទួលខុសត្រូវផ្ទាល់លើការងារសកម្មភាពជាក់

ស្តែងរបស់អង្គភាពនិងយាយជារួមគឺសំដៅទៅការអនុវត្តផ្ទាល់ទៅលើផែនការដែលបានដាក់ចេញដើម្បីទទួលបានជាប្រយោជន៍ទៅតាមគោលបំណងខាងលើ(ក្រសួងអប់រំ យុវជន និងកីឡា,២០១៦)។

### ២.២.៣. មុខងារនៃការគ្រប់គ្រង

ការគ្រប់គ្រងជាការធ្វើឱ្យប្រសើរឡើងនូវគុណផលសិក្សារបស់សិស្ស តាមរយៈនៃការគ្រប់គ្រងលើការអនុវត្តលើកម្មវិធីសិក្សា ការបង្រៀនការវាយតម្លៃកម្មវិធីសិក្សានិងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅកម្រិតសាលារៀន(ក្រសួងអប់រំ យុវជន និងកីឡា,២០១៨)។ ដើម្បីអោយការងារគ្រប់គ្រងមានដំណើរការល្អគេបានបែងចែកចេញជាបួនដំណាក់កាលសំខាន់ៗគឺ ១)ការធ្វើផែនការៈ គឺជាដំណើរការដំបូងមួយដែលអ្នកគ្រប់គ្រងត្រូវមានសកម្មភាពមួយចំនួនដូចជា ការកំណត់គោលដៅរបស់អង្គភាពការគ្រោងផែនការនិងរៀបចំយុទ្ធសាស្ត្រផ្សេងៗ ការដាក់ចេញនូវគោលនយោបាយកម្មវិធី និងបែបបទផ្សេងៗ ការកំណត់ថវិកា និងបទដ្ឋាននៃការចំណូលចំណាយ ដើម្បីសម្របសម្រួលសកម្មភាពការងារ។ ២)ការរៀបចំផែនការៈ គឺជាការរៀបចំចាត់ចែងមនុស្សឱ្យសមស្របតាមសមត្ថភាពបច្ចេកទេសនិងរចនាសម្ព័ន្ធ ដើម្បីឱ្យការងារមានដំណើរការល្អ មានរបៀបរៀបរយនិងរីកចម្រើន។ ៣)ការដឹកនាំផែនការៈ គឺជាករផ្តល់កម្លាំងចិត្ត លើកទឹកចិត្ត ដឹកនាំបុគ្គលិក ជ្រើសរើស បញ្ជប់ប្រាស្រ័យទាក់ទង និងដោះស្រាយជម្លោះ។ ការដឹកនាំរួមមានសកម្មភាពរស់រវើក។ ៤)ការត្រួតពិនិត្យលើផែនការៈ គឺជាការត្រួតពិនិត្យតាមដាននិងវាយតម្លៃដើម្បីធានាការងារសម្រេចតាមផែនការនិងធ្វើការកែសម្អប្ញកែតម្រូវប្រការណាមួយដែលខ្វះចន្លោះប្រហោង ដោយផ្អែកលើទិន្នន័យផ្លូវការ(ដូចជា របាយការណ៍ ការប្រជុំ សិក្ខាសាលា ការចុះធ្វើអធិការកិច្ចដល់ទីកន្លែង...) និង ទិន្នន័យក្រៅផ្លូវការ(ដូចជា ឮគេថា សារព័ត៌មាន ទស្សនកិច្ចឯកជន...)(ក្រសួងអប់រំ យុវជន និងកីឡា,២០១៦)។

### ២.២.៤. តួនាទីនៃការគ្រប់គ្រង

ការសិក្សាជាច្រើនស្តីអំពីតួនាទីរបស់អ្នកគ្រប់គ្រងបានសន្និដ្ឋានជារួមថាមានបីយ៉ាងសំខាន់ៗ គឺ ១)តួនាទីជាអន្តរបុគ្គលៈ យើងអាចនិយាយបានថាអ្នកគ្រប់គ្រងម្នាក់អាចដើរតួនាទី ជាអ្នកតំណាង ជាអ្នកដឹកនាំ ឬជាអ្នកទំនាក់ទំនង។ ២)តួនាទីគ្រប់គ្រងព័ត៌មានៈ អ្នកគ្រប់គ្រងអាចដើរតួជា អ្នកមើលការខុសត្រូវ ជាអ្នកផ្សព្វផ្សាយ ឬជាអ្នកនាំពាក្យ។ ៣)តួនាទីធ្វើការសម្រេចចិត្តៈ អ្នកគ្រប់គ្រង អាចជាសហគ្រិន ជាអ្នកដោះស្រាយបញ្ហា ឬជាអ្នកបែងចែកធនធាន(ក្រសួងអប់រំ យុវជន និងកីឡា,២០១៦)។

## ២.៣. ការអប់រំភាសាអង់គ្លេសនៅប្រទេសកម្ពុជា

សារៈសំខាន់នៃភាសាអង់គ្លេសនាសម័យសកលភាវូបនីយកម្ម បានជំរុញឱ្យរដ្ឋាភិបាលនៃប្រទេសជាច្រើននៅលើសកលលោក ងាកមកផ្តោតការយកចិត្តទុកដាក់លើកម្មវិធីអប់រំភាសាបរទេសមួយនេះ។ ជាក់ស្តែងនៅប្រទេសកម្ពុជាភាសាអង់គ្លេសត្រូវបានដាក់បញ្ចូលជាផ្លូវការនៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិចាប់ពីកម្រិតទី៤រហូតដល់ថ្នាក់ទី១២(ក្រសួងអប់រំ យុវជន និងកីឡា,២០១៥)។

ការកែលម្អកម្មវិធីសិក្សាភាសាអង់គ្លេសជាកត្តាចំបាច់ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងការសិក្សាស្រាវជ្រាវ ក្នុងការទទួលយកចំណេះដឹងថ្មីៗ ពីបច្ចេកវិទ្យាទំនើប ក៏ដូចជាការងារទំនាក់ទំនងវប្បធម៌ ការទូត ពាណិជ្ជកម្ម សេដ្ឋកិច្ច និងនយោបាយក្នុងតំបន់ និងលើសកលលោក(ក្រសួងអប់រំ យុវជន និងកីឡា,២០១៥)។

រាជរដ្ឋាភិបាលបានយល់យ៉ាងច្បាស់ថា វិស័យអប់រំ ជាវិស័យគន្លឹះមួយរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាព មានជំនាញខ្ពស់ ស្របតាមនិន្នាការវិចម្រើនរបស់សកលភាវូបនីយកម្ម។ ធនធានមនុស្ស ជាកម្លាំងចលករមួយចាំបាច់ក្នុងការអភិវឌ្ឍប្រទេសជាតិ។ គោលដៅអប់រំនៅសាលារៀនចំណោះទូទៅ គឺការកសាងធនធានមនុស្សឱ្យក្លាយជាពលរដ្ឋពេញលេញ ដែលប្រកបដោយចំណេះដឹង សីលធម៌ និងជំនាញ(ក្រសួងអប់រំ យុវជន និងកីឡា,២០១៨)។

ដើម្បីសម្រេចគោលដៅនេះ ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលជាបន្តបន្ទាប់។ កម្មវិធីសិក្សានេះ បានរៀបចំសម្រាប់សាលាមធ្យមសិក្សាចំណោះទូទៅ ពីថ្នាក់ទី១ដល់ថ្នាក់ទី១២(ក្រសួងអប់រំ យុវជន និងកីឡា,២០១៥)។ តាមរយៈកម្មវិធីសិក្សានេះសិស្សអាចប្រើប្រាស់ភាសាអង់គ្លេសក្នុងជីវភាពសង្គមបានក្នុងកម្រិតងាយមានភាពក្លាហានក្នុងការនិយាយស្តី ហ៊ានចោទសួរ និងឆ្លើយនូវសំណួរផ្សេងៗ ទាក់ទងទៅនឹងជីវភាពរស់នៅជាក់ស្តែងក្នុងសង្គមមានសមត្ថភាពក្នុងការសរសេរបានត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ចេះអាន និងយល់អត្ថបទពោលគឺភ្ជាប់ការសិក្សានិងការរស់នៅជាក់ស្តែង។ ក្នុងមុខនាទីនេះ ភាសាអង់គ្លេសត្រូវរួមចំណែកបណ្តុះបណ្តាលកុលបុត្រខ្មែរឱ្យក្លាយជាពលរដ្ឋដែលមានមនសិការ និងទទួលខុសត្រូវក្នុងភារកិច្ចដើម្បីឱ្យគេបានចូលរួមក្នុងកិច្ចអភិវឌ្ឍប្រទេស។ ការអប់រំភាសាអង់គ្លេសក្នុងកម្មវិធីសិក្សាថ្មីនៅកម្រិតមធ្យមសិក្សាទុតិយភូមិនេះ នឹងធ្វើឱ្យអ្នកសិក្សាទទួលបាននូវសមត្ថភាពនៃភាសាពិតប្រាកដ ទាំងការសរសេរ ការអាន ការស្តាប់ និងការនិយាយ កត្តាទាំងនេះជាចំណេះដឹង និងបំណិនជាមូលដ្ឋានសម្រាប់ប្រើប្រាស់ក្នុងការលើកកម្ពស់សមត្ថភាពក្នុងជីវភាពរស់នៅប្រចាំថ្ងៃ(ក្រសួងអប់រំ យុវជន និងកីឡា,២០០១)។

### ២.៣.១. គោលបំណងនៃការសិក្សាភាសាអង់គ្លេស

ភាសាបរទេសគឺជាភាសាយានក្នុងការប្រាស្រ័យទាក់ទង ការសិក្សាស្រាវជ្រាវ ការប្រកបកិច្ចការងារ ការអភិវឌ្ឍការគិត ការវិភាគ និងការច្នៃប្រឌិតឱ្យឆ្លើយតបទៅនឹងការផ្លាស់ប្តូរសង្គម និងការជឿនលឿនផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាក្នុងតំបន់ និងសកលលោក។ ភាសាអង់គ្លេសមានសារៈប្រយោជន៍ទូលំទូលាយក្នុងការសិក្សា និងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដែលមានសមាសភាគដូចជា ការស្តាប់ ការអាន ការនិយាយ និងការសរសេរ (ក្រសួងអប់រំ យុវជន និងកីឡា,២០១៥)។ នៅក្នុងកម្រិតថ្នាក់មធ្យមសិក្សាទុតិយភូមិនេះការសិក្សាមុខវិជ្ជាភាសាអង់គ្លេសមានគោលបំណងសំខាន់ផ្សេងទៀតដូចជា៖ ១)វិជ្ជាសម្បទា ជាសមត្ថភាពក្នុងការយល់និងបង្កើតការស្រូបយកចំណេះដឹងផ្នែកភាសាអង់គ្លេស សម្រាប់ប្រើប្រាស់ក្នុងការលើកកម្ពស់គុណភាពនិងសមត្ថភាព។ ពង្រីកចំណេះដឹង និងការយល់ដឹងពីបរិបទផ្សេងៗ

ប្រកបដោយអាកប្បកិរិយានិងឥរិយាបថល្អ។ ២)បំណិនសម្បទា ជាការបង្ហាញពីសមត្ថភាព ប្រើប្រាស់ភាសាអង់គ្លេសដើម្បីដោះស្រាយបញ្ហា។ បង្ហាញពីគំនិតច្នៃប្រឌិតនិងការបង្កើតថ្មីដើម្បីចូលរួមក្នុងការអភិវឌ្ឍសង្គម។ ៣)ចរិយាសម្បទា ជាការបណ្តុះគំនិតវិនិច្ឆ័យនិងពន្យល់ពីបាតុភូតដែលទាក់ទងនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យាសង្គម។ បណ្តុះឥរិយាបថនិងគុណធម៌ដល់មនុស្សឱ្យស្របតាមតម្លៃអ្នកសិក្សាភាសាអង់គ្លេស(ក្រសួងអប់រំ យុវជន និងកីឡា,២០០១៨)។

### ២.៣.២. របាយម៉ោងសិក្សា

របាយម៉ោងសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ត្រូវបានបែងចែកដូចក្នុងតារាងខាងក្រោម៖(ក្រសួងអប់រំ យុវជន និងកីឡា,២០១៥)។

តារាងទី2៖របាយម៉ោងសម្រាប់កម្រិតវិទ្យាល័យ

| ថ្នាក់ | ម៉ោង | សប្តាហ៍ | ឆ្នាំ |
|---|---|---|---|
| ទី១០ | ៤ម៉ោង/១សប្តាហ៍ | ៣៥សប្តាហ៍/១ឆ្នាំ | ១៤០ម៉ោង/១ឆ្នាំ |
| ទី១១ | ៤ម៉ោង/១សប្តាហ៍ | ៣៥សប្តាហ៍/១ឆ្នាំ | ១៤០ម៉ោង/១ឆ្នាំ |
| ទី១២ | ៤ម៉ោង/១សប្តាហ៍ | ៣៥សប្តាហ៍/១ឆ្នាំ | ១៤០ម៉ោង/១ឆ្នាំ |

### ២.៣.៣. ការអនុវត្តការណែនាំ

ដើម្បីសម្រេចគោលបំណង និងការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅមធ្យមសិក្សាទុតិយភូមិទទួលបានជោគជ័យយើងត្រូវ៖ ១)បំណែងចែកកម្មវិធីសិក្សានិងកិច្ចតែងការបង្រៀនឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំនិងមានសកម្មភាពច្បាស់លាស់តាមមេរៀននីមួយៗ ២)រៀបចំមេរៀនឱ្យទាក់ទងគ្នារំលឹកឡើងវិញវាយតម្លៃដើម្បីបំពេញចំណុចខ្វះខាតរបស់សិស្ស។ គ្រូត្រូវប្រើសំណួរបំផុសរួចសំយោគចម្លើយពីសិស្សមកវិញ។ ៣)រៀបចំសកម្មភាពបង្រៀននិងរៀនស្របតាមកម្មវិធីសិក្សាលទ្ធផលសិក្សានិងបរិស្ថានសិក្សា។ ក្នុងការរៀបចំកិច្ចតែងការបង្រៀនគ្រូត្រូវគោរពតាមប្រាំជំហាន៖ រដ្ឋបាលថ្នាក់រំលឹកមេរៀនចាស់ បង្រៀនមេរៀនថ្មី ពង្រឹងចំណេះដឹង និងដាក់កិច្ចការផ្ទះឱ្យសិស្សឬណែនាំសិស្សឱ្យ

ស្វ័យសិក្សាមេរៀនបន្ត។ ៤)ធ្វើសកម្មភាពស្របតាមស្ថានភាពរស់នៅរបស់សិស្សនៅជុំវិញបរិបទជីវភាព វប្បធ៌មជាតិខ្មែរ និងតថភាពជាក់ស្តែងនៃជីវភាពរស់នៅប្រចាំថ្ងៃ។ ៥.ជ្រើសរើសនិងផលិតសម្ភារឧបទេស ងាយៗដែលមានតាមមូលដ្ឋានជាក់ស្តែងឬច្នៃប្រឌិតក្នុងការបង្រៀន(ក្រសួងអប់រំ យុវជន និងកីឡា ,២០១៦)។

### ២.៣.៣.១. វិធីសាស្ត្របង្រៀន

ការបង្រៀនគឺជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្សដើម្បីឱ្យពួកគេមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដោយប្រើប្រាស់វិធីសាស្ត្រសិស្សមជ្ឈមណ្ឌលជាគោល។ ការបង្រៀនគឺ ជាសកម្មភាពជួយនិងលើកទឹកចិត្តសិស្សឱ្យចេះពីរបៀបរៀនដោយខ្លួនឯងយ៉ាងសកម្មមានប្រសិទ្ធភាព និងទទួលខុសត្រូវ ដើម្បីស្វែងយល់ធ្វើវិចារ អនុវត្តចំណេះដឹងសម្រាប់ការសិក្សា ការរស់នៅប្រចាំថ្ងៃ ដោយ ប្រើប្រាស់វិធីសាស្ត្រដូចជា សហការ សង្កេត និងអនុវត្តជាក់ស្តែង(ក្រសួងអប់រំ យុវជន និងកីឡា ,២០០២) ។ ការបង្រៀនត្រូវបន្តពង្រឹង និងពង្រីកចំណេះដឹង បទពិសោធ ទេពកោសល្យ និងចំណង់ ចំណូលចិត្តរបស់សិស្ស ដើម្បីឱ្យពួកគេស្រឡាញ់ និងផ្តល់តម្លៃ ដល់ការសិក្សា។ ការណែនាំ សម្រប សម្រួលរាល់ការនាំសកម្មភាពសិក្សានៅក្នុងថ្នាក់ សាលារៀន និងក្រៅសាលានូវរបៀប និងរៀន ត្រូវយក ចិត្តទុកដាក់លើខ្លឹមសារមេរៀនឱ្យបានច្បាស់លាស់ដោយឱ្យសិស្សមានការហ្វឹកហាត់ អនុវត្តដោយផ្ទាល់ និងមានការវាយតម្លៃជាប្រចាំ។ រៀបចំសិស្សឱ្យមានសកម្មភាពដូចជា ល្បែងដើរតួ ពិភាក្សា ការស្រាវជ្រាវ ដោយបណ្តុះនូវស្មារតី សហការ ចូលរួម សាមគ្គីភាព ភាពជាម្ចាស់ ការទទួលខុសត្រូវតាមតួនាទី និងភារ កិច្ចក្រុម ក្រោមការសម្របសម្រួលពីគ្រូបង្រៀន(ក្រសួងអប់រំ យុវជន និងកីឡា,២០១០)។

### ២.៣.៣.២. ការប្រើប្រាស់សម្ភារៈ

សម្ភារឧបទេសជាមធ្យោបាយ និងជាលក្ខខណ្ឌចាំបាច់សម្រាប់ប្រើប្រាស់ក្នុងដំណើរការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ សម្ភារឧបទេសរួមមាន៖ រូបភាពផ្ទាំងធំ បណ្ណរូបភាព

បណ្ណពាក្យ សៀវភៅសិក្សាគោល សៀវភៅណែនាំជាដើម គឺជាធនធានដែលគ្រូ និងសិស្សយកមកប្រើប្រាស់ក្នុងការបង្រៀន និងរៀន ដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែជាក់លាក់ ច្បាស់លាស់ ងាយយល់ ងាយចាប់បាន មានការទាក់ទាញអារម្មណ៍សិស្សហើយអាចសម្រេចវត្ថុបំណងមេរៀនបានល្អប្រសើរ។

គ្រូត្រូវឱ្យសិស្សសង្កេត ពិចារណា ពិភាក្សា និងហាត់ប្រើសម្ភារៈដោយខ្លួនឯងដើម្បីយល់ច្បាស់ពីខ្លឹមសារមេរៀន។ កត្តាសំខាន់គ្រូត្រូវកំណត់សម្ភារៈបង្រៀនឱ្យបានច្បាស់លាស់ទៅតាមតម្រូវការនៃមេរៀននីមួយៗ(ក្រសួងអប់រំ យុវជន និងកីឡា,២០១០)។

### ២.៣.៤. ការវាយតម្លៃ

ការវាយតម្លៃការអប់រំ គឺជាដំណើរការវាយតម្លៃនៃការកំណត់លក្ខណៈ និងវាយតម្លៃទិដ្ឋភាពមួយចំនួននៃដំណើរការអប់រំ។ មានគោលបំណងទូទៅពីរក្នុងការវាយតម្លៃអប់រំ ដែលជួនកាលមានជម្លោះជាមួយគ្នា។ ស្ថាប័នអប់រំជាធម្មតាទាមទារទិន្នន័យវាយតម្លៃដើម្បីបង្ហាញពីប្រសិទ្ធភាពដល់អ្នកផ្តល់មូលនិធិ និងអ្នកពាក់ព័ន្ធផ្សេងទៀត និងដើម្បីផ្តល់នូវរង្វាស់នៃការអនុវត្តសម្រាប់គោលបំណងទីផ្សារ។ ការវាយតម្លៃការអប់រំក៏ជាសកម្មភាពវិជ្ជាជីវៈដែលអ្នកអប់រំបុគ្គលត្រូវអនុវត្ត ប្រសិនបើពួកគេមានបំណងពិនិត្យមើលជាបន្តបន្ទាប់ និងលើកកំពស់ការរៀនសូត្រដែលពួកគេកំពុងព្យាយាមសម្របសម្រួល(ក្រសួងអប់រំ យុវជន និងកីឡា,២០១០)។

#### ២.៣.៤.១. វិធីវាយតម្លៃ

នៅក្នុងការវាយតម្លៃគេអាចប្រើវិធីពីរសំខាន់ៗដូចជាៈ១)រង្វាយតម្លៃជាប្រចាំនៅពេលបង្រៀនចប់មេរៀននីមួយៗ ដើម្បីស្ទាបស្ទង់ការយល់ដឹងរបស់សិស្ស លើមេរៀនដែលបានបង្រៀនហើយ និងស្វែងរកគំនិតភាន់ច្រឡំរបស់សិស្ស ដើម្បីជួយពួកគេឱ្យទាន់ពេលវេលា និងដើម្បីឱ្យពួកគេមានលទ្ធភាពផ្លាស់ប្តូរឥរិយាបថទៅតាមស្ថានភាពជាក់ស្តែង។ ២)រង្វាយតម្លៃសរុបមានគោលបំណងស្ទាបស្ទង់ វាយតម្លៃសមត្ថភាព និងលទ្ធផលសិក្សាសរុបរបស់សិស្ស(ក្រសួងអប់រំ យុវជន និងកីឡា,២០១០)។

### ២.៣.៤.២. រូបភាពវាយតម្លៃ

នៅក្នុងការវាយតម្លៃនូវសមត្ថភាពនៃកាសិក្សារបស់សិស្សត្រូវបានធ្វើឡើងតាមរយៈរូបភាពជាច្រើនដែលមានដូចជាៈការដកស្រង់ខ្លឹមសារមេរៀនចាំបាច់មួយចំនួន មកធ្វើជាសំណួរផ្ទាល់មាត់ សំណួរសរសេរ ធ្វើតេស្ត ក្នុងការប្រឡងប្រចាំខែ ឆមាស ស្របតាមភាពជាក់ស្តែងដែលមានក្នុងកម្មវិធីសិក្សា ការអនុវត្តផ្ទាល់ ធ្វើកិច្ចការជាក្រុមឬដៃគូ លេងល្បែងសិក្សា ស្វ័យសិក្សា និងកិច្ចការផ្ទះ។ (ក្រសួងអប់រំ យុវជន និងកីឡា,២០១៤)។

# ជំពូក៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូក៣៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. គម្រោងវិភាគ

នៅក្នុងការសិក្សាស្រាវជ្រាវនេះដើម្បីអោយទទួលបានពត៏ត៌មានក៏ដូចជាទិន្នន័យគ្រប់គ្រាន់សម្រាប់យកមកធ្វើការវិភាគវែកញែក អ្នកស្រាវជ្រាវបានរៀបចំគម្រោងវិភាគយ៉ាងច្បាស់លាស់និងយកចិត្តទុកដាក់ខ្ពស់ទៅតាមដំណាក់កាលនីមួយៗ នៃដំណើរការស្រាវជ្រាវទាំងមូល ដោយបានធ្វើការកំណត់ថាបន្ទាប់ពីចុះប្រមូលទិន្នន័យបានគ្រប់គ្រាន់រួចរាល់អស់ហើយនោះ អ្នកស្រាវជ្រាវគ្រោងនឹងវិភាគតាមកម្រងសំណួរនីមួយៗតាមលក្ខណៈបរិមាណវិស័យ ទៅតាមផ្នែកដែលបានកំណត់ជាលំដាប់លំដោយចាប់ពីកម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេស និងសិស្សានុសិស្សថ្នាក់ទី១០ ទី១១ និងទី១២ ដែលមានរៀបរាប់តាមចំណុចដូចជា៖

### ៣.១.១. កម្រងសំណួរ

#### ក.កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា

គោលបំណងនៃកម្រងសំណួរសំរាប់គណៈគ្រប់គ្រងសាលាគឺដើម្បីសួរចង់ដឹងអំពីព័ត៌មានជាក់លាក់មួយចំនួនដែលទាក់ទងទៅនឹង ព័ត៌មានទូទៅ ការយល់ឃើញ ការគ្រប់គ្រង បញ្ហាប្រឈម របស់នាយកសាលាលើឯកទេសភាសាអង់គ្លេស។

#### ផ្នែកទី១៖ ព័ត៌មានទូទៅ

នៅក្នុងផ្នែកនេះយើងអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពីព័ត៌មានផ្ទាល់ខ្លួន និងកន្លែងបម្រើការងាររបស់ពួកគាត់ដែលមានដូចជា៖ ឈ្មោះសាលារៀន ទីលំនៅបច្ចុប្បន្ន មុខតំណែង បទពិសោធន៍ការងារ ភេទ អាយុ ឯកទេស កម្រិតវប្បធម៌។

## ផ្នែកទី២៖ការយល់ឃើញរបស់គណៈគ្រប់គ្រងសាលាទៅលើមុខវិជ្ជាភាសាអង់គ្លេស

នៅក្នុងផ្នែកនេះយើងចង់ដឹងអំពីការយល់ឃើញរបស់គណៈគ្រប់គ្រងសាលាចំពោះអត្ថប្រយោជន៍នៃមុខវិជ្ជាភាសាអង់គ្លេសដែលមានដូចជា៖

១) សារៈសំខាន់ភាសាអង់គ្លេសចំពោះការសិក្សានិងការស្រាវជ្រាវ។

២) សារៈសំខាន់ភាសាអង់គ្លេសចំពោះការចិញ្ចឹមជីវិតនាពេលបច្ចុប្បន្ន។

៣) សារៈសំខាន់ភាសាអង់គ្លេសទៅថ្ងៃអនាគត។

## ផ្នែកទី៣៖ ការគ្រប់គ្រងការបង្រៀននិងរៀនលើមុខវិជ្ជាភាសាអង់គ្លេស

នៅក្នុងផ្នែកនេះអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពីការងារគ្រប់គ្រងលើការបង្រៀនភាសាអង់គ្លេសរបស់លោកគ្រូអ្នកគ្រូដែលមានដូចជា៖

១) សេចក្តីណែនាំស្តីអំពីកម្មវិធីសិក្សាភាសាអង់គ្លេសនៅថ្នាក់ទី១០ ទី១១ ទី១២។

២) សៀវភៅសិក្សាគោលភាសាអង់គ្លេស នៅថ្នាក់ទី១០ ទី១១ ទី១២។

៣) ម៉ោងសិក្សាភាសាអង់គ្លេសនៅថ្នាក់ទី១០ ទី១១ ទី១២។

៤) សមត្ថភាពនិងទេព្យកោសល្យរបស់គ្រូបង្រៀនភាសាអង់គ្លេសនៅថ្នាក់ទី១០ ទី១១ ទី១២។

៥) កិច្ចតែងការបង្រៀននិងសម្ភារៈឧបទ្ទេសរបស់គ្រូភាសាអង់គ្លេសនៅថ្នាក់ទី១០ ទី១១ ទី១២។

៦) ការវាយតម្លៃលើគុណភាពនិងលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាភាសាអង់គ្លេសដែលគ្រូបានបង្រៀនកន្លងមកនៅថ្នាក់ទី១០ ទី១១ ទី១២។

៧) ការចុះអធិការកិច្ចលើដំណើរការបង្រៀនភាសាអង់គ្លេសនៅថ្នាក់ទី១០ ទី១១ ទី១២។

៨) ការសិក្សារបស់សិស្សានុសិស្ស

**ផ្នែកទី៤៖បញ្ហាប្រឈមលើការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេស**

នៅក្នុងផ្នែកនេះយើងចង់ដឹងពីការលំបាកខ្លាំងរបស់នាយកសាលាទៅលើការគ្រប់គ្រងការបង្រៀនភាសាអង់គ្លេសចំពោះបុគ្គលិកដែលមានដូចជា៖

១) កត្តាសាលារៀន។

២) កត្តាគ្រូបង្រៀន។

៣) កត្តាសិស្ស។

៤) កត្តាមជ្ឈដ្ឋានជុំវិញនិងសង្គម

**ខ.កម្រងសំណួរសម្រាប់គ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី១០ ទី១១ និង ទី១២**

គោលបំណងនៃកម្រងសំណួរសំរាប់គ្រូបង្រៀនគឺដើម្បីសួរចង់ដឹងអំពីព័ត៌មានជាក់លាក់មួយចំនួនដែលទាក់ទងទៅនឹង ព័ត៌មានទូទៅ ការគ្រប់គ្រង បញ្ហាប្រឈម ការយល់ឃើញរបស់គ្រូបង្រៀនទៅលើឯកទេសភាសាអង់គ្លេស។

**ផ្នែកទី១៖ ព័ត៌មានទូទៅ**

នៅក្នុងផ្នែកនេះយើងខ្ញុំចង់ដឹងអំពីព័ត៌មានផ្ទាល់ខ្លួន និងកន្លែងបម្រើការងាររបស់ពួកគាត់ដែលមានដូចជា៖ ឈ្មោះសាលារៀន ទីលំនៅបច្ចុប្បន្ន ថ្នាក់បង្រៀន បទពិសោធន៍ការងារ ភេទ អាយុ មុខវិជ្ជាឯកទេស កម្រិតវប្បធម៌។

**ផ្នែកទី២៖ការយល់ឃើញរបស់គ្រូបង្រៀនចំពោះមុខវិជ្ជាភាសាអង់គ្លេស**

នៅក្នុងផ្នែកនេះយើងចង់ដឹងអំពីការយល់ឃើញរបស់លោកគ្រូអ្នកគ្រូដែលបង្រៀនភាសាអង់គ្លេសចំពោះអត្ថប្រយោជន៍នៃមុខវិជ្ជាភាសាអង់គ្លេសដែលមានដូចជា៖

១) សារៈសំខាន់ភាសាអង់គ្លេសចំពោះការសិក្សានិងការស្រាវជ្រាវ។

២) សារៈសំខាន់ភាសាអង់គ្លេសចំពោះការចិញ្ចឹមជីវិតនាពេលបច្ចុប្បន្ន។

៣) សារៈសំខាន់ភាសាអង់គ្លេសទៅថ្ងៃអនាគត។

**ផ្នែកទី៣៖ ការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេស**

នៅក្នុងនេះយើងខ្ញុំចង់ដឹងអំពីការងារគ្រប់គ្រងថ្នាក់រៀននិងការបង្រៀនរបស់លោកគ្រូអ្នកគ្រូលើមុខវិជ្ជាភាសាអង់គ្លេសដែលមានដូចជា៖

១) សេចក្តីណែនាំស្តីពីកម្មវិធីសិក្សាភាសាអង់គ្លេស

២) សៀវភៅសិក្សាគោលភាសាអង់គ្លេស

៣) ម៉ោងសិក្សាភាសាអង់គ្លេសតាមថ្នាក់នីមួយៗ

៤) សមត្ថភាពនិងទេពកោសល្យរបស់គ្រូបង្រៀនភាសាអង់គ្លេស

៥) កិច្ចតែងការបង្រៀននិងសម្ភារៈឧបទ្ទេសរបស់គ្រូភាសាអង់គ្លេស

៦) ការវាយតម្លៃលើគុណភាពនិងលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាភាសាអង់គ្លេសដែលគ្រូបានបង្រៀនកន្លងមក។

៧) ការចុះអធិការកិច្ចលើដំណើរការបង្រៀនភាសាអង់គ្លេស

៨) ការសិក្សារបស់សិស្សានុសិស្ស

**ផ្នែកទី៤៖បញ្ហាប្រឈមក្នុងការបង្រៀនភាសាអង់គ្លេស**

នៅក្នុងផ្នែកនេះយើងចង់ដឹងពីការលំបាកខ្លាំងរបស់គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសទៅលើការការបង្រៀនភាសាអង់គ្លេសដែលមានដូចជា៖

១) កត្តាសាលារៀន

២) កត្តាគ្រូបង្រៀន

៣) កត្តាសិស្ស

៤) កន្លាមផ្សព្វផ្សានខាងក្រៅ

**គ.កម្រងសំណួរសំរាប់សិស្សានុសិស្សនៅថ្នាក់ទី១០ ទី១១ និង ទី១២**

គោលបំណងនៃកម្រងសំណួរសំរាប់សិស្សគឺដើម្បីសួរចង់ដឹងអំពីព័ត៌មានជាក់លាក់មួយចំនួន ដែលទាក់ទងទៅនឹង ព័ត៌មានទូទៅ ការយល់ឃើញរបស់សិស្ស ការសិក្សាភាសាអង់គ្លេស បញ្ហាប្រឈម របស់សិស្សទៅលើមុខវិជ្ជាភាសាអង់គ្លេស។

**ផ្នែកទី១៖ ព័ត៌មានទូទៅ**

នៅក្នុងផ្នែកនេះអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពីព័ត៌មានផ្ទាល់ខ្លួន និងកន្លែងសិក្សារៀនសូត្រ របស់ពួកគាត់ដែលមានដូចជា៖ ឈ្មោះសាលារៀន ភេទ អាយុ កម្រិតថ្នាក់

**ផ្នែកទី២៖ការយល់ឃើញរបស់សិស្សានុសិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស**

នៅក្នុងផ្នែកនេះអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពីការយល់ឃើញរបស់សិស្សចំពោះអត្ថប្រយោជន៍នៃមុខវិជ្ជាភាសាអង់គ្លេសដែលមានដូចជា៖

១) សារៈសំខាន់ភាសាអង់គ្លេសសំរាប់ការងារ

២) សារៈសំខាន់ភាសាអង់គ្លេសសំរាប់ការសិក្សា

៣) សារៈសំខាន់ភាសាអង់គ្លេសទៅអនាគត។

៤) ចំណាង់ចំណូលចិត្តរបស់សិស្សក្នុងការសិក្សាភាសាអង់គ្លេស។

**ផ្នែកទី៣៖ ការសិក្សាភាសាអង់គ្លេសរបស់សិស្សានុសិស្ស**

នៅក្នុងនេះអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពីការសិក្សាភាសាអង់គ្លេសរបស់សិស្សានុសិស្ស ដែលមានដូចជា៖

១) ការទទួលបានសៀវភៅសិក្សាមុខវិជ្ជាភាសាអង់គ្លេស

២) ការទទួលបានម៉ោងសិក្សាភាសាអង់គ្លេស

៣) ការបង្រៀនរបស់គ្រូភាសាអង់គ្លេស

៤) ការប្រើប្រាស់សម្ភារៈឧបទ្ទេសរបស់គ្រូបង្រៀននៅក្នុងថ្នាក់

៥) ការវាយតម្លៃលើគុណភាពនិងលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាភាសាអង់គ្លេសដែលគ្រូបានបង្រៀនកន្លងមក។

៦) ការយល់ដឹងអំពីមេរៀនដែលគ្រូបង្រៀន

៧)មូលដ្ឋានគ្រឹះភាសាអង់គ្លេសនៅថ្នាក់ក្រោម

**ផ្នែកទី៤៖បញ្ហាប្រឈមក្នុងការបង្រៀនភាសាអង់គ្លេស**

នៅក្នុងផ្នែកនេះអ្នកសិក្សាស្រាវជ្រាវចង់ដឹងអំពីការលំបាករបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស ដែលមានដូចជា៖

១) កត្តាសាលារៀន

២) កត្តាគ្រូបង្រៀន

៣) កត្តាសិស្ស

៤) កត្តាមជ្ឈដ្ឋានខាងក្រៅ

## ៣.២. ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងបន្ទាប់ពីមានការរៀបចំឧបករណ៍ស្រាវជ្រាវបានរួចរាល់និងត្រួតពិនិត្យកែសម្រួលបានត្រឹមត្រូវរួចអស់ហើយ។ ព្រមទាំងបានទទួលការឯកភាពពីសំណាក់ភាគីដែលពាក់ព័ន្ធនៅក្នុងនោះមានដូចជា ក្រសួងអប់រំយុវជននិងកីឡា គណៈគ្រប់គ្រងនៃវិទ្យាស្ថានជាតិអប់រំ សាស្ត្រចារ្យណែនាំបង្គោល សាស្ត្រាចារ្យណែនាំរង ព្រមទាំងមានការសហការជាមួយប្រធានមន្ទីរ អប់រំ យុវ

ជននិងកីឡា ខេត្តតាកែវ ការិយាល័យអប់រំស្រុកព្រៃកប្បាស និងគណៈគ្រប់គ្រងសាលាវិទ្យាល័យដែលជាសាលាគោលដៅដែលត្រូវចុះទៅប្រមូលទិន្នន័។

មុនពេលចាប់ផ្តើមចុះទៅប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវសំរាប់ជាកិច្ចបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ នៅវិទ្យាស្ថានជាតិអប់រំ អ្នកសិក្សាត្រូវមានលិខិតឧទ្ទេសនាមដែលបានអនុញ្ញាតចាត់តាំងឱ្យចុះប្រមូលទិន្នន័យដែលចេញដោយវិទ្យាស្ថានជាតិអប់រំ បន្ទាប់មកអ្នកស្រាវជ្រាវបាននាំយកលិខិតនេះទៅកាន់មន្ទីរអេប់រំយុវជននិងកីឡា ខេត្តតាកែវ ដើម្បីអោយមន្ទីរជួយចេញនូវលិខិតមួយផ្សេងទៀតដើម្បីជាការជូនដំណឹងទៅដល់សាលាដែលជាក្រុមគោលដៅដែលបានកំណត់ទុកសំរាប់ធ្វើការស្រង់យកព័ត៌មាន។ បន្ទាប់ពីបានទទួលនូវលិខិតបញ្ជាក់ពីមន្ទីរអេប់រំយុវជននិងកីឡាខេត្តតាកែវរួចហើយ អ្នកស្រាវជ្រាវបានយកលិខិតនេះទៅជូនការិយាល័យអប់រំស្រុកព្រៃកប្បាស ដើម្បីចូលរួមសហការក្នុង ការចុះប្រមូលទិន្នន័យនៅតាមសាលាគោលដៅដែលបានជ្រើសរើសនិងចាប់ផ្តើមនៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ ដល់ ថ្ងៃទី៣០ខែកក្កដា ឆ្នាំ២០២២។ នៅពេលដែលទទួលបានការអនុញ្ញាតទៅតាមឋានានុក្រមរួចអស់ហើយ អ្នកស្រាវជ្រាវបានចុះទៅជួបផ្ទាល់ជាមួយគណៈគ្រប់គ្រងសាលានីមួយៗ ក្នុងចំណោមសាលាវិទ្យាល័យគោលដៅទាំង០៨ ដែលស្ថិតនៅក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ ដើម្បីធ្វើការស្នើសុំអនុញ្ញាតជួបជាមួយគណៈគ្រប់គ្រងសាលា លោកគ្រូអ្នកគ្រូដែលបង្រៀនភាសាអង់គ្លេស សិស្សានុសិស្ស នៅថ្នាក់ទី១០ ទី១១ ទី១២។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំអោយគណៈគ្រប់គ្រងសាលាជួយសម្របសម្រួលទៅដល់ដំណើរការស្រង់យកព័ត៌មានដោយជួយជ្រើសរើសគ្រូបង្រៀនភាសាអង់គ្លេសនិងសិស្សានុសិស្សតាមចំនួនដែលបានគ្រងទុកជាស្រេចដើម្បីមកបំពេញកម្រងសំណួរ។ មុនពេលបំពេញកម្រងសំណួរអ្នកសិក្សាស្រាវជ្រាវបានពន្យល់ពីគោលបំណងនៃការចុះទៅប្រមូលទិន្នន័យ និងធ្វើការស្នើសុំដើម្បីអោយក្រុមគោលដៅទាំងអស់បំពេញកម្រងសំណួរអោយបានត្រឹមត្រូវនិងបានទាំងអស់គ្នា។

## ៣.៣. ឧបករណ៍ស្រាវជ្រាវ

ស្ថិតនៅក្នុងការស្រាវជ្រាវនេះដើម្បីទទួលបានព័ត៌មានត្រឡប់មកវិញជាទិន្នន័យនិងខ្លឹមសារសំខាន់នានាអំពីការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យ យើងបានប្រើប្រាស់កម្រងសំណួរជាទម្រង់ Microsoft Office Word សំរាប់ធ្វើជាឧបករណ៍ស្រាវជ្រាវ ដែលអាចអនុញ្ញាតឱ្យគណៈគ្រប់គ្រងសាលា លោកគ្រូអ្នកគ្រូ រួមជាមួយសិស្សានុសិស្សអាច ផ្តល់ទិន្នន័យទៅតាមលំដាប់លំដោយស្របតាមការរៀបចំនៅក្នុងទម្រង់កម្រងសំណួរនីមួយៗបានតាមការពិតជាក់ស្តែង។ សំរាប់កម្រងសំណួរនេះយើងបានរៀបចំជាបីប្រភេទគឺ

១.កម្រងសំនួរសម្រាប់គណៈគ្រប់គ្រងសាលារៀនដែលមានដូចជា គណៈគ្រប់គ្រងសាលា (នាយក នាយករង នាយិកា និងនាយិការង)។

២.កម្រងសំណួរសម្រាប់លោកគ្រូអ្នកគ្រូបង្រៀនភាសាអង់គ្លេសនៅថ្នាក់ទី១០ ទី១១ និងទី១២។

៣.កម្រងសំណួរសម្រាប់សិស្សានុសិស្សដែលសិក្សានៅថ្នាក់ទី១០ ទី១១ និងទី១២។

## ៣.៤. ការជ្រើសរើសសំណាក

តំបន់គោលដៅដែលអ្នកស្រាវជ្រាវត្រូវចុះទៅប្រមូលនិន្នន័យគឺស្ថិតនៅក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ ដែលមានឃុំទាំងអស់ចំនួន១៣ឃុំ និង វិទ្យាល័យចំនួន០៨សាលា ស្ថិតក្នុងឃុំចំនួន០៨ ដែលមានទីតាំងដូចខាងក្រោម៖

១)វិទ្យាល័យកំពែង ដែលស្ថិតនៅក្នុង ឃុំកំពែង ស្រុកព្រៃកប្បាស ខេត្តតាកែវ។

២)វិទ្យាល័យក្រាំងស្លា ដែលស្ថិតនៅក្នុង ឃុំចា ស្រុកព្រៃកប្បាស ខេត្តតាកែវ។

៣)វិទ្យាល័យចំប៉ា ដែលស្ថិតនៅក្នុង ឃុំចំប៉ា ស្រុកព្រៃកប្បាស ខេត្តតាកែវ។

៤)វិទ្យាល័យបានយ ដែលស្ថិតនៅ ឃុំអង្កាញ់ ស្រុកព្រៃកប្បាស តាកែវ។

៥)វិទ្យាល័យភ្នីមាស ដែលស្ថិតនៅក្នុង ឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ។

៦)វិទ្យាល័យសមរលោវ ដែលស្ថិតនៅក្នុង ឃុំពោធិ៍រំចាក ស្រុកព្រៃកប្បាស ខេត្តតាកែវ។

៧)វិទ្យាល័យហេងសំរិន ព្រៃល្វា ដែលស្ថិតនៅក្នុង ឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តកែវ។

៨)វិទ្យាល័យអង្គអណ្ដែត ដែលស្ថិតនៅក្នុង ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។

## ៣.៥. ការវិភាគនិន្នន័យ

ការសិក្សាស្រាជ្រាវមួយនេះគឺត្រូវបានធ្វើឡើងតាមបែបបរិមាណវិស័យ។ ហេតុដូចនេះហើយរាល់ការប្រមូលទិន្នន័យទាំងអស់គឺត្រូវបានយកមកធ្វើការវិភាគក្នុងកុំព្យូទ័រ(computer) ដោយប្រើប្រាស់កម្មវិធី Microsoft Office Excel។

# ជំពូក៤
# លទ្ធផលស្រាវជ្រាវ
# និង
# ការពិភាក្សា

# ជំពូក៤៖ លទ្ធផលស្រាវជ្រាវនិងការពិភាក្សា

## ៤.១. គណៈគ្រប់គ្រងសាលា

### ៤.១.១. ព័ត៌មានទូទៅ

តារាងទី3៖ព័ត៌មានលំអិតអំពីគណៈគ្រប់គ្រង

<table>
<tr><th rowspan="2">ចំនួន</th><th colspan="2">ភេទ</th><th colspan="2">អាយុ</th><th colspan="2">សញ្ញាបត្រ</th><th colspan="2">តួនាទី</th></tr>
<tr><th>ប្រុស</th><th>ស្រី</th><th>ចន្លោះ</th><th>ចំនួន</th><th>ប្រភេទ</th><th>ចំនួន</th><th>នាយក</th><th>នាយករង</th></tr>
<tr><td rowspan="5">23</td><td rowspan="5">22</td><td rowspan="5">1</td><td>[30-35]</td><td>2</td><td>បណ្ឌិត</td><td>0</td><td rowspan="5">8</td><td rowspan="5">15</td></tr>
<tr><td rowspan="4">[លើសពី35]</td><td rowspan="4">21</td><td>អនុបណ្ឌិត</td><td>0</td></tr>
<tr><td>បរិញ្ញាបត្រ</td><td>20</td></tr>
<tr><td>បរិញ្ញាបត្ររង</td><td>0</td></tr>
<tr><td>ស.ទុតិយភូមិ</td><td>3</td></tr>
</table>

តាមតារាងខាងលើបានបង្ហាញអំពីព័ត៌មានលំអិតអំពីនាយកសាលាដែលរាប់បញ្ចូលទាំង នាយក នាយករង នាយិកា និង នាយិការងដែលមានចំនួនសរុបទាំងអស់ ២៣នាក់ ស្មើរនឹង១០០%។ ក្នុងនេះដែរភេទប្រុសមានចំនួនសរុប២២នាក់ ស្មើនឹង ៩៥.៦៥% និង ភេទស្រីមានចំនួនសរុប ១នាក់ស្មើនឹង ៤.៣៤%។

ចំពោះចន្លោះអាយុយើងឃើញថា អាយុពីចន្លោះ ៣០ឆ្នាំ ដល់ ៣៥ឆ្នាំ មានចំនួនសរុប ២នាក់ ស្មើនឹង ៨.៦៩%។ រីឯអាយុដែលលើសពី៣៥ឆ្នាំទៅមានចំនួនសរុប២១នាក់ ស្មើនឹង ៩១.៣០%។

ចំពោះសញ្ញាបត្រយើងឃើញថាលោកគ្រូអ្នកគ្រូដែលមានសញ្ញាបត្របរិញ្ញាបត្រមានចំនួនសរុប ២០នាក់ ស្មើនឹង៨៦.៩៥% និង សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានចំនួនសរុប ៣នាក់ ស្មើនឹង ១៣.០៤%។

### ៤.១.២. ការយល់ឃើញរបស់គណៈគ្រប់គ្រងសាលាចំពោះមុខវិជ្ជាភាសាអង់គ្លេស

#### ៤.១.២.១. សារៈសំខាន់ភាសាអង់គ្លេសចំពោះការសិក្សានិងការស្រាវជ្រាវ

ក្រាបទី1៖សារៈសំខាន់ភាសាអង់គ្លេសចំពោះការសិក្សានិងការស្រាវជ្រាវ




ក្រាបខាងលើបង្ហាញពីការយល់ឃើញរបស់គណៈគ្រប់គ្រងសាលាចំពោះសារៈសំខាន់នៃភាសាអង់គ្លេសសំរាប់ការសិក្សានិងការស្រាវជ្រាវនៅសាលាទាំង០៨ ក្នុងស្រុកព្រៃកប្បាសតាមរយៈសូចនាករនៅក្នុងកម្រងសំណួរដែលមានចំនួន១១៥ ស្មើនឹង១០០% ។ តាមក្រាបបានបង្ហាញថា ចំណុចខ្សោយគឺមិនមានទេ។ ចំណែកឯមធ្យមមាន០៩ ស្មើនឹង៧.៨២%។ ល្អបង្គួរមាន៤៤ ស្មើនឹង៣៨.២៦%។ ល្អមានចំនួន៤០ ស្មើនឹង៣៤.៧៨%។ ល្អណាស់មានចំនួន២២ ស្មើនឹង១៩.១៣%។

ដូចនេះតាមក្រាបបានបង្ហាញថាការយល់ឃើញរបស់នាយកសាលាទាំង០៨ចំពោះសារៈសំខាន់ភាសាអង់គ្លេសគឺស្ថិតនៅត្រឹមកម្រិតល្អបង្គួរនៅឡើយ ដែលមានចំនួនភាគរយខ្ពស់ជាងគេគឺ៣៨.២៦%។

### ៤.១.២.២. សារៈសំខាន់ភាសាអង់គ្លេសចំពោះការងារចិញ្ចឹមជីវិតនាពេលបច្ចុប្បន្ន

ក្រាបទី2៖សារៈសំខាន់ភាសាអង់គ្លេសចំពោះការងារចិញ្ចឹមជីវិតនាពេលបច្ចុប្បន្ន




តាមក្រាបខាងលើបានបង្ហាញពីការយល់ឃើញរបស់គណៈគ្រប់គ្រងសាលាចំពោះសារៈសំខាន់ភាសាអង់គ្លេសសំរាប់ការងារចិញ្ចឹមជីវិតនាពេលបច្ចុប្បន្ន ដែលមានចំនួន១១៥ ស្មើនឹង១០០%។ នៅក្នុងនេះយើងឃើញថា ខ្សោយគឺមិនមានទេ រីឯមធ្យមមានចំនួន៩ ស្មើនឹង៧.៨២%។ ល្អបង្គួរមានចំនួន៣៣ ស្មើនឹង២៨.៦៩%។ ល្អមានចំនួន៥០ ស្មើនឹង៤៣.៤៧%។ ល្អណាស់មានចំនួន២៣ ស្មើនឹង២០%។

ដូចនេះតាមក្រាបបានបង្ហាញថាការយល់ឃើញរបស់គណៈគ្រប់គ្រងសាលាចំពោះសារៈសំខាន់ភាសាអង់គ្លេសលើការងារចិញ្ចឹមជីវិតសព្វថ្ងៃគឺស្ថិតនៅកម្រិតល្អដែលមានភាគរយខ្ពស់ជាងគេរហូតដល់៤៣.៤៧%។

### ៤.១.២.៣. សារៈសំខាន់ភាសាអង់គ្លេសទៅថ្ងៃអនាគត

ក្រាបទី3៖សារៈសំខាន់ភាសាអង់គ្លេសទៅថ្ងៃអនាគត




ក្រាបខាងលើបានបង្ហាញពីការយល់ឃើញរបស់គណៈគ្រប់គ្រងសាលាចំពោះសារៈសំខាន់ភាសាអង់គ្លេសទៅថ្ងៃអនាគតដែលមានចំនួន១១៥ ស្មើនឹង១០០%។ តាមរយៈក្រាបនេះយើងឃើញថាកម្រិតខ្សោយគឺមិនមានឡើង ចំណែកឯមធ្យមមានចំនួន២ ស្មើនឹង១.៧៣%។ ល្អបង្គួរមាន២២ ស្មើនឹង១៩.១៣%។ ល្អមាន៥៩ ស្មើនឹង៥១.៣០%។ ល្អណាស់មានចំនួន៣២ ស្មើនឹង២៧.៨២%។

ដូចនេះតាមក្រាបបានបង្ហាញថាការយល់ឃើញរបស់គណៈគ្រប់គ្រងសាលាចំពោះសារៈសំខាន់ភាសាអង់គ្លេសទៅថ្ងៃអនាគតគឺស្ថិតនៅកម្រិតល្អដែលមានភាគរយខ្ពស់ជាងគេគឺ៥១.៣០% និងមិនទាន់ឈានដល់កម្រិតល្អណាស់នៅឡើយទេ។

### ៤.១.៣. ការគ្រប់គ្រងលើការបង្រៀននិងរៀនលើមុខវិជ្ជាភាសាអង់គ្លេស

#### ៤.១.៣.១. សេចក្តីណែនាំស្តីពីការបង្រៀនភាសាអង់គ្លេស

ក្រាបទី4៖សេចក្តីណែនាំស្តីពីការបង្រៀនភាសាអង់គ្លេស




ក្រាបខាងលើបង្ហាញពីការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេសដែលពាក់ព័ន្ធជាមួយនិងសេចក្តីណែនាំស្តីពីការបង្រៀននិងរៀនភាសាអង់គ្លេសដែលមានចំនួនសរុប៦៦ ស្មើនឹង១០០%។ តាមរយៈក្រាបនេះយើងឃើញថា កម្រិតខ្សោយមិនមាននោះទេ។ កម្រិតមធ្យមក៏មិនមានដែរ។ កម្រិតល្អបង្គួរមានចំនួន២៦ ស្មើនឹង៣៩.៣៩%។ កម្រិតល្អមានចំនួន៣៣ ស្មើនឹង៥០%។ កម្រិតល្អណាស់មានចំនួន៧ ស្មើនឹង១០.៦០%។

ដូចនេះតាមរយៈក្រាបខាងលើយើងឃើញថាការគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលាពាក់ព័ន្ធជាមួយនឹងសេចក្តីណែនាំមានការយល់ដឹងច្រើនក្នុងកម្រិតល្អគឺ៥០% ដែលជាកម្រិតមួយខ្ពស់ជាងគេអាចទទួលយកបាន។

### ៩.១.៣.២. សៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេសកម្រិតវិទ្យាល័យ

ក្រាបទី5៖សៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេសកម្រិតវិទ្យាល័យ




ក្រាបខាងលើបង្ហាញពីការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេសដែលពាក់ព័ន្ធជាមួយសៀវភៅសិក្សាគោលដែលមានចំនួនសរុប១១៤ ស្មើនឹង១០០%។ តាមរយៈក្រាបនេះយើងឃើញថាកម្រិតខ្សោយគឺមិនមាននោះទេ។ កម្រិតមធ្យមមាន៧ ស្មើនឹង៦.១៤%។ កម្រិតល្អបង្គួរមាន៣៧ ស្មើនឹង៣២.៤៥%។ កម្រិតល្អមាន៤៤ ស្មើនឹង៣៨.៥៩%។ កម្រិតល្អណាស់មាន២៦ ស្មើនឹង២២.៨០%។

តាមរយៈក្រាបខាងលើយើងឃើញថាការគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលាចំពោះសៀវភៅសិក្សាគោលគឺស្ថិតនៅក្នុងកម្រិតមួយដែលល្អនិងមានភាគរយគឺ៣៨.៥៩%ដែលមានភាគរយខ្ពស់ជាងគេ។

### ៤.១.៣.៣. ម៉ោងសិក្សាភាសាអង់គ្លេសតាមថ្នាក់នីមួយៗ

ក្រាបទី6៖ម៉ោងសិក្សាតាមថ្នាក់នីមួយៗ




ក្រាបខាងលើបង្ហាញពីការគ្រប់គ្រងការបង្រៀននិងរៀនទៅលើម៉ោងសិក្សាដែលមានចំនួនសរុប ៩២ ស្មើនឹង១០០%។ តាមរយៈក្រាបនេះយើងឃើញថានៅកម្រិត ខ្សោយនិងមធ្យមមិនមានជាតួលេខនោះទេ។ កម្រិតល្អបង្គួរមានចំនួន៨ ស្មើនឹង៨.៦៩%។ កម្រិតល្អមានមាន៤៧ ស្មើនឹង៥១.០៨%។ កម្រិតល្អណាស់មាន៣៧ ស្មើនឹង៤០.២១%។

ដូចនេះតាមរយៈការបង្ហាញរបស់ក្រាបខាងលើយើងឃើញថាម៉ោងសិក្សាតាមថ្នាក់នីមួយៗស្ថិតនៅក្នុងកម្រិតល្អដែលមានភាគរយ៥១.០៨%គឺជាភាគរយខ្ពស់ជាងគេ។

### ៤.១.៣.៤. សមត្ថភាពនិងទេពកោសល្យរបស់គ្រូបង្រៀនភាសាអង់គ្លេស

ក្រាបទី7៖សមត្ថភាពនិងទេពកោសល្យរបស់គ្រូបង្រៀនភាសាអង់គ្លេស




ក្រាបខាងលើបង្ហាញពីការគ្រប់គ្រងការបង្រៀននិងរៀនរបស់គណៈគ្រប់គ្រងសាលាទាំង៨ដែលផ្តោតទៅលើសមត្ថភាពនិងទេពកោសល្យរបស់គ្រូដែលកំពុងបង្រៀននៅកម្រិតវិទ្យាល័យដែលមានចំនួនសរុប១៨៣ ស្មើនឹង១០០%។ តាមរយៈក្រាបខាងលើយើងឃើញថាកម្រិតខ្សោយមិនមានចំនួនតួលេខទេ។ កម្រិតមធ្យមមានចំនួនសរុប១៦ ស្មើនឹង៨.៧៣%។ កម្រិតល្អបង្គួរមាន៧០ ស្មើនឹង៣៨.២៥%។ កម្រិតល្អមានចំនួនសរុប៨៧ ស្មើនឹង៤៧.៥៤%។ កម្រិតល្អណាស់មានចំនួន១០ ស្មើនឹង៥.៤៦%។

តាមរយៈក្រាបខាងលើយើងឃើញថាសមត្ថភាពគ្រូគឺស្ថិតនៅកម្រិតល្អដែលមាន៤៧.៥៤%ដែលជាភាគរយខ្ពស់ជាងគេ។

### ៤.១.៣.៥. កិច្ចតែងការបង្រៀននិងសម្ភារៈឧបទ្ទេសរបស់លោកគ្រូអ្នកគ្រូ

ក្រាបទី៨៖កិច្ចតែងការបង្រៀននិងសម្ភារៈឧបទ្ទេសរបស់លោកគ្រូអ្នកគ្រូ




ក្រាបខាងលើបង្ហាញពីការគ្រប់គ្រងការបង្រៀននិងរៀនរបស់គណៈគ្រប់គ្រងសាលាទាំង៨ដែលផ្តោតទៅលើកិច្ចតែងការបង្រៀននិងសម្ភារៈឧបទ្ទេសរបស់លោកគ្រូអ្នកគ្រូដែលកំពុងបង្រៀននៅកម្រិតវិទ្យាល័យមានចំនួនសរុប១៣៨ ស្មើនឹង១០០%។ តាមរយៈក្រាបខាងលើយើងឃើញថាកម្រិតខ្សោយមិនមានជាតួលេខនោះទេ។ កម្រិតមធ្យមមានចំនួន១ដែលស្មើនឹង០.៧២%។ កម្រិតល្អបង្គួរមានចំនួន៥០ ស្មើនឹង៣៦.២៣%។ កម្រិតល្អមានចំនួន៧៩ ស្មើនឹង៥៧.២៥%។ កម្រិតល្អណាស់មានចំនួន៨ ស្មើនឹង ៥.៧៩%។

ដូចនេះតាមរយៈក្រាបខាងលើយើងឃើញថាការគ្រប់គ្រងទៅលើការប្រើប្រាស់កិច្ចតែងការនិងសម្ភារៈឧបទ្ទេសស្ថិតនៅក្នុងកម្រិតល្អដែលមាន៥៧.២៥%។

### ៤.១.៣.៦. ការវាយតម្លៃលទ្ធផលសិក្សាភាសាអង់គ្លេសប្រចាំខែរបស់សិស្ស

ក្រាបទី៩៖ការវាយតម្លៃលទ្ធផលសិក្សាភាសាអង់គ្លេសប្រចាំខែរបស់សិស្ស




ក្រាបខាងលើបង្ហាញពីកិច្ចការងារគ្រប់គ្រងការបង្រៀននិងរៀនរបស់គណៈគ្រប់គ្រងសាលាទាំង៨ ដែលផ្តោតទៅលើការវាយតម្លៃលទ្ធផលសិក្សាភាសាអង់គ្លេសប្រចាំខែរបស់សិស្សដែលមានចំនួនសរុប៦៩ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថាកម្រិតខ្សោយនិងមធ្យមមិនមានចំនួនជាតួលេខនោះទេ។ កម្រិតល្អបង្គួរមានចំនួន២៣ ស្មើនឹង៣៣.៣៣%។ កម្រិតល្អមានចំនួន៣៤ ស្មើនឹង៤៩.២៧%។ កម្រិតល្អណាស់មានចំនួន១២ ស្មើនឹង១៧.៣៩%។

ដូចនេះជាលទ្ធផលបង្ហាញថាការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាប្រចាំខែគឺបានប្រព្រឹត្តិទៅស្ថិតនៅក្នុងកម្រិតល្អបានច្រើនជាងគេដែលមាន៤៩.២៧%។

### ៤.១.៣.៧. ការចុះអធិការកិច្ចលើដំណើរការបង្រៀនភាសាអង់គ្លេស

ក្រាបទី10៖ការចុះអធិការកិច្ចលើដំណើរការបង្រៀនភាសាអង់គ្លេស




ក្រាបខាងលើបង្ហាញពីការចុះអធិការកិច្ចរបស់នាយកសាលាលើដំណើរការបង្រៀននិងរៀនភាសាអង់គ្លេសដែលមានចំនួនសរុប៦៩ ស្មើនឹង១០០%។ តាមក្រាបបានបង្ហាញថាកម្រិតខ្សោយនិងមធ្យមគឺមិនមានបង្ហាញជាតួលេខនោះទេ។ កម្រិតល្អបង្គួរមានចំនួន២៨ ស្មើនឹង៤០.៥៧%។ កម្រិតល្អមាន៣៦ ស្មើនឹង៥២.១៧%។ កម្រិតល្អណាស់មាន៥ ស្មើនឹង៧.២៤%។

ដូចនេះតាមក្រាបបានបង្ហាញថាការចុះអធិការកិច្ចរបស់គណៈគ្រប់គ្រងសាលាគឺស្ថិតនៅក្នុងកម្រិតល្អច្រើនដែលមាន៥២.១៧%ជាភាគរយខ្ពស់ជាងគេ។

### ៩.១.៣.៨. ការសិក្សារបស់សិស្សានុសិស្ស

ក្រាបទី11៖ការសិក្សារបស់សិស្សានុសិស្ស




ក្រាបខាងលើបង្ហាញពីការគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលាចំពោះការសិក្សារបស់សិស្សដែលមានចំនួន១១៤ ស្មើនឹង១០០%។ តាមរយៈក្រាបខាងលើយើងឃើញថាកម្រិតខ្សោយគឺមិនមានជាតួលេខនោះទេ។ កម្រិតមធ្យមមានចំនួន៤ ស្មើនឹង៣.៥០%។ កម្រិតល្អបង្គួរមាន៥៥ ស្មើនឹង៤៨.២៤%។ កម្រិតល្អមាន៤៩ ស្មើនឹង៤២.៩៨%។ កម្រិតល្អណាស់មាន៦ ស្មើនឹង៥.២៦%។

ដូចនេះការសិក្សារបស់សិស្សចំពោះភាសាអង់គ្លេសគឺនៅមិនទាន់ទទួលបានល្អនោះទេបានត្រឹមតែកម្រិតល្អបង្គួរ៤៨.២៤%ដែលទាមទារអោយមានការកែលម្អរាល់ចំណុចខ្វះខាតចំពោះការសិក្សារបស់សិស្សបន្ថែមតទៅទៀត។

### ៤.១.៤. បញ្ហាប្រឈមលើការគ្រប់គ្រងការបង្រៀននិងរៀនលើមុខវិជ្ជាភាសាអង់គ្លេស

#### ៤.១.៤.១. កត្តាសាលារៀន

ក្រាបទី12៖កត្តាសាលារៀន




ក្រាបខាងលើបង្ហាញពីបញ្ហាប្រឈមរបស់គណៈគ្រងសាលាលើការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេសដែលពាក់ព័ន្ធជាមួយនិងកត្តាសាលារៀនដែលមានជាតួលេខតាមរយៈសូចនាករសរុបចំនួន៩១ ស្មើនឹង១០០%។ តាមរយៈក្រាបបានបង្ហាញថាកម្រិតខ្សោយមានចំនួន២៩ ស្មើនឹង៣១.៨៦%។ កម្រិតមធ្យមមាន២៣ ស្មើនឹង២៥.២៧%។ កម្រិតល្អបង្គួរមាន១៩ ស្មើនឹង២០.៨៧%។ កម្រិតល្អមានចំនួន១៣ ស្មើនឹង១៤.២៨%។ កម្រិតល្អណាស់មានចំនួន៧ ស្មើនឹង៧.៦៩%។

ដូចនេះតាមរយៈក្រាបខាងលើយើងឃើញថាបញ្ហាប្រឈមចំពោះការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេសដែលមានការទាក់ទងជាមួយសាលារៀនគឺមាននៅមានជាបញ្ហាចោទច្រើនដោយកម្រិតល្អណាស់នៅមានបង្ហាញជាតួលេខនិងមានចំនួន៧.៦៩%ដែលត្រូវមានការដោះស្រាយអោយប្រសើរឡើងវិញ។

### ៩.១.៩.២. កត្តាគ្រូបង្រៀន

ក្រាបទី13៖កត្តាគ្រូបង្រៀន




ក្រាបខាងលើបង្ហាញពីបញ្ហាប្រឈមលើការគ្រប់គ្រងការបង្រៀននិងរៀនរបស់គណៈគ្រប់គ្រងសាលាដែលពាក់ព័ន្ធជាមួយគ្រូបង្រៀននៅក្នុងនេះមានចំនួន១១៥ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថាកម្រិតខ្សោយមានចំនួន៤៤ ស្មើនឹង៣៨.២៦%។ កម្រិតមធ្យមមានចំនួន៤៣ ស្មើនឹង៣៧.៣៩%។ កម្រិតល្អបង្គួរមានចំនួន២០ ស្មើនឹង១៧.៣៩%។ កម្រិតល្អមានចំនួន៨ ស្មើនឹង។ កម្រិតល្អណាស់មិនមានបង្ហាញជាតួលេខទេ។

ដូចនេះកត្តាគ្រូបង្រៀនគឺនៅមានចោទជាបញ្ហានៅឡើយដោយកម្រិតល្អនៅមានចំនួន៦.៩៥%។

### ៤.៤.១. ៣កត្តាសិស្ស.

ក្រាបទី14៖កត្តាសិស្ស




ក្រាបខាងលើបង្ហាញពីបញ្ហាប្រឈមដែលពាក់ព័ន្ធជាមួយនិងកត្តាសិស្សដែលមានចំនួន១១៥ ស្មើនឹង១០០%។ តាមក្រាបបង្ហាញថាកម្រិតខ្សោយមាន៤០ ស្មើនឹង៣៤.៧៨%។ កម្រិតមធ្យមមាន៤៨ ស្មើនឹង៤១.៧៣%។ កម្រិតល្អបង្គួរមាន១០ ស្មើនឹង៨.៦៩%។ កម្រិតល្អមាន១៣ ស្មើនឹង១១.៣០%។ កម្រិតល្អណាស់មាន៤ ស្មើនឹង៣.៤៧%។

ដូចនេះតាមក្រាបបង្ហាញថាកត្តាសិស្សនៅមានចោទជាបញ្ហានៅឡើយដោយកម្រិតល្អណាស់នៅមានបង្ហាញចំនួន៣.៤៧%។

### ៤.១.៤.៤. កត្តាមជ្ឈដ្ឋានជុំវិញនិងសង្គម

ក្រាបទី15៖កត្តាមជ្ឈដ្ឋានជុំវិញនិងសង្គម




ក្រាបខាងលើបង្ហាញពីបញ្ហាប្រឈមជាមួយនិងមជ្ឈដ្ឋានជុំវិញខ្លួនរបស់សិស្សដែលមាន១១៤ ស្មើនឹង ១០០%។ តាមក្រាបយើងឃើញថាកម្រិតខ្សោយមាន៦១ ស្មើនឹង៥៣.៥០%។ កម្រិតមធ្យមមាន៣១ ស្មើនឹង២៧.១៩%។ កម្រិតល្អបង្គួរមាន១០ ស្មើនឹង៨.៧៧%។ កម្រិតល្អមាន១១ ស្មើនឹង៩.៦៤%។ កម្រិតល្អណាស់មាន១ ស្មើនឹង០.៨៧%។

ដូចនេះបញ្ហាប្រឈមជាមួយនឹងមជ្ឈដ្ឋានជុំវិញគឺមានចោទជាបញ្ហាតិចតួចដែរដោយកម្រិតល្អណាស់មាន០.៨៧%។

## ៤.២. គ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី១០ ទី១១ និងទី១២

### ៤.២.១. ព័ត៌មានទូទៅ

តារាងទី4៖ព័ត៌មានលំអិតអំពីគ្រូបង្រៀនភាសាអង់គ្លេស

| ចំនួន | ភេទ | | អាយុ | | សញ្ញាបត្រ | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ចន្លោះ | ចំនួន | ប្រភេទ | ចំនួន |
| 21 | 18 | 3 | [20-25] | 1 | បណ្ឌិត | |
| | | | [26-30] | 3 | អនុបណ្ឌិត | 1 |
| | | | [31-35] | 6 | បរិញ្ញាបត្រ | 18 |
| | | | [លើស35] | 11 | បរិញ្ញាបត្ររង | |
| | | | | | ស.ទុតិយភូមិ | 2 |

តារាងខាងលើបានបង្ហាញអំពីព័ត៌មានលំអិតរបស់គ្រូបង្រៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យ ដែលមានចំនួនសរុបទាំងអស់ ២១នាក់ ស្មើរនឹង១០០%។ ក្នុងនេះដែរភេទប្រុសមានចំនួនសរុប១៨នាក់ ស្មើនឹង ៨៥.៧១% និង ភេទស្រីមានចំនួនសរុប ៣នាក់ស្មើនឹង ១៤.២៨%។

ចំពោះចន្លោះអាយុយើងឃើញថា អាយុពីចន្លោះ 20ឆ្នាំ ដល់ 25ឆ្នាំ មានចំនួនសរុប 1នាក់ ស្មើនឹង ៤.៧៦%។ រីឯអាយុពី២៦ឆ្នាំ ដល់ ៣០ទៅមានចំនួន ៣នាក់ ស្មើនឹង ១៤.២៨%។ អាយុ៣១ឆ្នាំ ដល់ ៣៥ឆ្នាំមាន ៦នាក់ ស្មើនឹង២៨.៥៧%។ អាយុចាប់ពី៣៦ឆ្នាំឡើងទៅមាន១១នាក់ ស្មើនឹង៥២.៣៨%។

ចំពោះសញ្ញាបត្រយើងឃើញថាលោកគ្រូអ្នកគ្រូដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមាន ចំនួន២នាក់ ស្មើនឹង៩.៥២%។ បរិញ្ញាបត្រមានចំនួនសរុប១៨នាក់ ស្មើនឹង៨៥.៧១% និង សញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់មានចំនួនសរុប ១នាក់ ស្មើនឹង ៤.៧៦%។

### ៤.២.២. ការយល់ឃើញរបស់គ្រូបង្រៀនចំពោះមុខវិជ្ជាភាសាអង់គ្លេស

#### ៤.២.២.១. សារៈសំខាន់ភាសាអង់គ្លេសចំពោះការសិក្សានិងការស្រាវជ្រាវ

ក្រាបទី16៖សារៈសំខាន់ភាសាអង់គ្លេសចំពោះការសិក្សានិងការស្រាវជ្រាវ




ក្រាបខាងលើបង្ហាញពីការយល់ឃើញរបស់លោកគ្រូអ្នកគ្រូចំពោះសារៈសំខាន់ភាសាអង់គ្លេសទៅលើការសិក្សានិងការស្រាវជ្រាវដែលមានចំនួនសរុប១០៥ ស្មើនឹង១០០%។ តាមក្រាបកម្រិតខ្សោយមានចំនួនសរុប០៩ ស្មើនឹង៨.៥៧%។ កម្រិតមធ្យមមានចំនួន១០ ស្មើនឹង៩.៥២%។ កម្រិតល្អបង្គួរមានចំនួន៣៤ ស្មើនឹង៣២.៣៨%។កម្រិតល្អមានចំនួន៣០ ស្មើនឹង២៨.៥៧%។ កម្រិតល្អណាស់មាន២២ ស្មើនឹង២០.៩៥%។

ដូចនេះចំពោះការយល់ឃើញរបស់លោកគ្រូអ្នកគ្រូចំពោះភាសាអង់គ្លេសទៅលើការសិក្សាស្រាវជ្រាវគឺស្ថិតនៅក្នុងកម្រិតល្អបង្គួរខ្ពស់ជាងគេគឺ៣២.៣៨%។

### ៤.២.២.២. សារៈសំខាន់ភាសាអង់គ្លេសចំពោះការងាចិញ្ចឹមជីវិត

ក្រាបទី17៖សារៈសំខាន់ភាសាអង់គ្លេសចំពោះការងារចិញ្ចឹមជីវិត




ក្រាបខាងលើនេះបង្ហាញពីការប្រើប្រាស់ភាសាអង់គ្លេសក្នុងការចិញ្ចឹមជីវិតប្រចាំថ្ងៃដែលមានចំនួនសរុប១០៦ ស្មើនឹង១០០%។ តាមក្រាមបង្ហាញថាកម្រិតខ្សោយមាន៥ ស្មើនឹង៤.៧២%។ កម្រិតមធ្យមមាន១២ ស្មើនឹង១១.៣២%។ កម្រិតល្អបង្គួរមាន២៦ ស្មើនឹង២៤.៥៣%។ កម្រិតល្អមាន៤០ស្មើនឹង៣៧.៧៤%។ កម្រិតល្អណាស់មាន២៣ ស្មើនឹង២១.៧០%។

ដូចនេះតាមក្រាបមានន័យថាការយល់ឃើញរបស់លោកគ្រូអ្នកគ្រូចំពោះភាសាអង់គ្លេសទៅថ្ងៃអនាគតគឺស្ថិតនៅក្នុងកម្រិតល្អគឺ៣៧.៧៤%ខ្ពស់ជាងគេ។

### ៤.២.២.៣. សារៈសំខាន់ភាសាអង់គ្លេសទៅថ្ងៃអនាគត

ក្រាបទី18៖សារៈសំខាន់ភាសាអង់គ្លេសទៅថ្ងៃអនាគត




ក្រាបខាងលើបង្ហាញពីការយល់ឃើញរបស់លោកគ្រូអ្នកគ្រូចំពោះភាសាអង់គ្លេសទៅថ្ងៃអនាគត ដែលមានចំនួនសរុប១០៤ ស្មើនឹង១០០%។ តាមក្រាបកម្រិតខ្សោយមាន៦ ស្មើនឹង៥.៧៧%។ កម្រិតមធ្យមមាន៥ ស្មើនឹង៤.៨១%។ កម្រិតល្អបង្គួរមាន១៣ ស្មើនឹង៣៣.៦៥%។ កម្រិតល្អមាន៣៥ ស្មើនឹង៣៣.៦៥% កម្រិតល្អណាស់៤៥ ស្មើនឹង៤៣.២៧%។

ដូចនេះការយល់ឃើញរបស់លោកគ្រូអ្នកគ្រូចំពោះភាសាអង់គ្លេសទៅថ្ងៃអនាគតគឺស្ថិតនៅក្នុងកម្រិតល្អណាស់ដែលមានភាគរយច្រើនជាងគេគឺ៤៣.២៧%។

### ៤.២.៣. ការគ្រប់គ្រងលើការបង្រៀននិងរៀនលើមុខវិជ្ជាភាសាអង់គ្លេស

#### ៤.២.៣.១. សេចក្តីណែនាំស្តីពីការបង្រៀនភាសាអង់គ្លេស

ក្រាបទី19៖សេចក្តីណែនាំស្តីពីការបង្រៀនភាសាអង់គ្លេស




ក្រាបខាងលើនិយាយអំពីសេចក្តីណែនាំស្តីពីការបង្រៀននិងរៀនភាសាអង់គ្លេសចំពោះគ្រូបង្រៀន ដែលមានចំនួនសរុប៦៣ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថាកម្រិតខ្សោយមានចំនួន១ ស្មើនឹង ១.៥៩%។ កម្រិតមធ្យមមាន៦ ស្មើនឹង៩.៥២%។ កម្រិតល្អបង្គួរមាន២៣ ស្មើនឹង៣៦.៥១%។ កម្រិតល្អមាន២៦ ស្មើនឹង៤១.២៧%។ កម្រិតល្អណាស់មាន៧ ស្មើនឹង១១.១១%។

ដូចនេះការយល់ដឹងអំពីសេចក្តីណែនាំរបស់គ្រូបង្រៀនចំពោះភាសាអង់គ្លេសគឺស្ថិតនៅក្នុងកម្រិតល្អខ្ពស់ជាងគេដែលមាន៤១.២៧%។

### ៤.២.៣.២. សៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេស

ក្រាបទី20៖សៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេស




ក្រាបខាងលើបង្ហាញពីការប្រើប្រាស់សៀវភៅសិក្សាគោលនៅក្នុងថ្នាក់ដែលមានចំនួនសរុបតាមសូចនាករ៤២ ស្មើនឹង១០០%។ តាមក្រាបខាងលើយើងបានកម្រិតខ្សោយមានមាន២ ស្មើនឹង៤.៧៦%។ កម្រិតមធ្យមមាន៧ ស្មើនឹង១៦.៦៧%។ កម្រិតល្អបង្គួរនិងកម្រិតល្អមាន១៣ ដូចគ្នានិងស្មើនឹង៣០.៩៥%ដូចគ្នាផងដែរ។ កម្រិតល្អណាស់មាន៧ ស្មើនឹង១៦.៦៧%។

ដូចនេះការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសគឺស្ថិតនៅក្នុងកម្រិតល្អបង្គួរនិងល្អហើយស្ថិតនៅក្នុងភាគរយខ្ពស់ជាងគេគឺ៣០.៩៥%។

### ៤.២.៣.៣. ម៉ោងសិក្សាភាសាអង់គ្លេសតាមថ្នាក់នីមួយៗ

ក្រាបទី21៖ម៉ោងសិក្សាភាសាអង់គ្លេសតាមថ្នាក់នីមួយៗ




ក្រាបខាងលើបង្ហាញពីម៉ោងសិក្សាតាមថ្នាក់នីមួយៗដែលមានចំនួនសរុប៨៤ ស្មើនឹង១០០%។ តាមក្រាបយើងបានកម្រិតខ្សោយមាន៤ ស្មើនឹង៤.៧៦%។ កម្រិតមធ្យមមាន៥ ស្មើនឹង៥.៩៥%។ កម្រិតល្អបង្គួរមាន១៣ ស្មើនឹង១៥.៤៨%។កម្រិតល្អមាន៣៤ ស្មើនឹង៤០.៤៨% កម្រិតល្អណាស់មាន ២៨ ស្មើនឹង៣៣.៣៣%។

ដូចនេះយើងឃើញថាម៉ោងសិក្សាភាសាអង់គ្លេសរបស់គ្រូគឺស្ថិតនៅក្នុងកម្រិតល្អដែលមានភាគរយខ្ពស់ជាងគេគឺ៤០.៤៨%។

### ៤.២.៣.៤. សមត្ថភាពនិងទេពកោសល្យរបស់គ្រូបង្រៀនតាមថ្នាក់នីមួយៗ

ក្រាបទី22៖សមត្ថភាពនិងទេពកោសល្យរបស់គ្រូបង្រៀនតាមថ្នាក់នីមួយៗ




ក្រាបខាងលើបង្ហាញពីសមត្ថភាពគ្រូនៅក្នុងការបង្រៀនសិស្សកម្រិតវិទ្យាល័យដែលមានចំនួនសរុប១៧០ ស្មើនឹង១០០%។ តាមក្រាបយើងបានកម្រិតខ្សោយមាន១៣ ស្មើនឹង៧.៦៥%។ កម្រិតមធ្យមមាន១៩ ស្មើនឹង១១.១៨%។ កម្រិតល្អបង្គួរមាន៤១ ស្មើនឹង២៤.១២%។ កម្រិតល្អមាន៦៥ ស្មើនឹង។ កម្រិតល្អណាស់មាន៣២ ស្មើនឹង១៨.៨២%។

ដូចនេះសមត្ថភាពគ្រូស្ថិតនៅក្នុងការបង្រៀននិងរៀនគឺស្ថិតនៅក្នុងកម្រិតល្អដែលមានភាគរយខ្ពស់ជាងគេគឺ៣៨.២៤%។

### ៤.២.៣.៥. កិច្ចតែងការបង្រៀននិងសម្ភារៈឧបទ្ទេសរបស់លោកគ្រូអ្នកគ្រូ

ក្រាបទី23៖កិច្ចតែងការបង្រៀននិងសម្ភារៈឧបទ្ទេសរបស់លោកគ្រូអ្នកគ្រូ




ក្រាបខាងលើបង្ហាញពីការប្រើប្រាស់កិច្ចតែងការនិងសម្ភារៈសិក្សារបស់គ្រូនៅក្នុងថ្នាក់ដែលមានចំនួនសរុប១២៣ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថាកម្រិតខ្សោយមាន៦ ស្មើនឹង៤.៨៨%។ កម្រិតមធ្យមមាន១៣ ស្មើនឹង១០.៥៧%។ កម្រិតល្អបង្គួរមាន៣៩ ស្មើនឹង៣១.៧១%។ កម្រិតល្អមាន៥៤ ស្មើនឹង៤៣.៩០%។ កម្រិតល្អណាស់មាន១១ ស្មើនឹង៨.៩៤%។

ដូចនេះការប្រើប្រាស់កិច្ចតែងការនិងសម្ភារៈសិក្សារបស់គ្រូក្នុងការបង្រៀនស្ថិតនៅក្នុងកម្រិតល្អខ្ពស់ជាងគេគឺ៤៣.៩០%។

### ៤.២.៣.៦. ការធ្វើតេស្តនិងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស

ក្រាបទី24៖ការធ្វើតេស្តនិងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស




ក្រាបខាងលើបង្ហាញពីការវាយតម្លៃការសិក្សារបស់សិស្សជាប្រចាំខែដែលមានចំនួនសរុប៦៣ ស្មើនឹង១០០%។ តាមក្រាបបង្ហាញថាកម្រិតខ្សោយមានចំនួន២ ស្មើនឹង៣.១៧%។ កម្រិតមធ្យមមាន៨ ស្មើនឹង១២.៧០%។ កម្រិតល្អបង្គួរមាន១៥ ស្មើនឹង២៣.៨១%។ កម្រិតល្អមាន២០ ស្មើនឹង៣១.៧៥%។ កម្រិតល្អណាស់មាន១៨ ស្មើនឹង២៨.៥៧%។

ដូចនេះក្រាបបានបង្ហាញថាការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាប្រចាំខែគឺស្ថិតនៅក្នុងលំដាប់ល្អខ្ពស់ជាងគេគឺ៣១.៧៥%។

### ៤.២.៣.៧. ការចុះអធិការកិច្ចលើដំណើរការបង្រៀនភាសាអង់គ្លេស

ក្រាបទី25៖ការចុះអធិការកិច្ចលើដំណើរការបង្រៀនភាសាអង់គ្លេស




ក្រាបខាងលើបង្ហាញពីការចុះអធិការកិច្ចចំពោះគ្រូពីគណៈគ្រប់គ្រងសាលាដែលមានចំនួនសរុប ៦២ ស្មើនឹង១០០%។ តាមក្រាបយើងបានកម្រិតខ្សោយមាន៥និងមធ្យមមាន៥ ដែលស្មើនឹង៨.០៦% ដូចគ្នា។ កម្រិតល្អបង្គួរមាន១៥ ស្មើនឹង២៤.១៩%។ កម្រិតល្អមាន២៥ ស្មើនឹង៤០.៣២%។ កម្រិតល្អណាស់មាន១២ ស្មើនឹង១៩.៣៥%។

ដូចនេះការចុះអធិការកិច្ចរបស់គណៈគ្រប់គ្រងសាលាចំពោះគ្រូគឺស្ថិតនៅក្នុងកម្រិតល្អខ្ពស់ជាងគេ គឺ៤០.៣២%។

### ៤.២.៣.៨. ការសិក្សារបស់សិស្សានុសិស្ស

ក្រាបទី26៖ការសិក្សារបស់សិស្សានុសិស្ស




ក្រាបខាងលើបង្ហាញពីការសិក្សារបស់សិស្សដែលមានចំនួនសរុប១២៥ ស្មើនឹង១០០%។ តាមក្រាបបានបង្ហាញថាកម្រិតខ្សោយមាន៦ ស្មើនឹង៤.៨០%។ កម្រិតមធ្យមមាន១៩ ស្មើនឹង១៥.២០%។ កម្រិតល្អបង្គួរមាន៤២ ស្មើនឹង៣៣.៦០%។ កម្រិតល្អមាន៥១ ស្មើនឹង។ កម្រិតល្អណាស់មាន៧ ស្មើនឹង ៥.៦០%។

ដូចនេះការសិក្សារបស់សិស្សគឺស្ថិតនៅក្នុងកម្រិតល្អដែលមានភាគរយខ្ពស់ជាងគេគឺ៤០.៨០%។

## ៤.២.៤. បញ្ហាប្រឈមលើការបង្រៀននិងរៀនលើមុខវិជ្ជាភាសាអង់គ្លេស

### ៤.២.៤.១. កត្តាសាលារៀន

ក្រាបទី27៖កត្តាសាលារៀន




ក្រាបខាងលើនិយាយពីបញ្ហាប្រឈមដែលគ្រូបានជួបប្រទះជាមួយការបង្រៀនពាក់ព័ន្ធជាមួយនិងកត្តាសាលារៀនដែលមានចំនួន៨៤ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថាកម្រិតខ្សោយមាន២៦ ស្មើនឹង៣០.៩៥%។ កម្រិតមធ្យមមាន៣០ ស្មើនឹង៣៥.៧១%។ កម្រិតល្អបង្គួរនិងល្អមាន១២ ដូចគ្នាស្មើនឹង១៤.២៩%ដូចគ្នា។ កម្រិតល្អណាស់មាន៤ ស្មើនឹង។

ដូចនេះបញ្ហាប្រឈមរបស់គ្រូនៅក្នុងការបង្រៀនភាសាអង់គ្លេសចំពោះកត្តាសាលារៀនគឺស្ថិតនៅក្នុងកម្រិតល្អណាស់គឺមាន៤.៧៦%។

### ៤.២.៤.២. កត្តាគ្រូបង្រៀន

ក្រាបទី28៖កត្តាគ្រូបង្រៀន




ក្រាបខាងលើបង្ហាញពីបញ្ហាប្រឈមផ្ទាល់ខ្លួនដែលគ្រូបានជួបប្រទះនៅក្នុងការបង្រៀននិងរៀន ដោយមានចំនួនសរុប១០៥ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថា កម្រិតខ្សោយមាន៣២ ស្មើនឹង ៣០.៤៨%។ កម្រិតមធ្យមមាន២៤ ស្មើនឹង២២.៨៦%។ កម្រិតល្អបង្គួរមាន២៦ ស្មើនឹង២៤.៧៦%។ កម្រិតល្អមាន១៩ ស្មើនឹង ១៨.១០%។ កម្រិតល្អណាស់មាន៤ ស្មើនឹង៣.៨១%។

ដូចនេះបញ្ហាប្រឈមរបស់គ្រូនៅមានចោទជាបញ្ហាដោយសារតែកម្រិតល្អណាស់នៅមាន ៣.៨១%។

### ៤.២.៤.៣. កត្តាសិស្ស

ក្រាបទី29៖កត្តាសិស្ស




ក្រាបខាងលើបង្ហាញពីបញ្ហាប្រឈមដែលគ្រូបានជួបប្រទះពាក់ព័ន្ធជាមួយសិស្សដែលមានចំនួនសរុប១០៥ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថាកម្រិតខ្សោយមាន២៥ ស្មើនឹង២៣.៨១%។ កម្រិតមធ្យមមាន៣៤ ស្មើនឹង៣២.៣៨%។ កម្រិតល្អបង្គួរមាន២៣ ស្មើនឹង២១.៩០%។ កម្រិតល្អមាន១៨ ស្មើនឹង១៧.១៤%។ កម្រិតល្អណាស់មាន៥ ស្មើនឹង៤.៧៦%។

ដូចនេះបញ្ហាប្រឈមរបស់គ្រូចំពោះការបង្រៀនដែលផ្ដោតទៅកត្តាសិស្សស្ថិតនៅក្នុងកម្រិតល្អណាស់មាន៤.៧៦%។

### ៤.២.៤.៤. កត្តាមជ្ឈដ្ឋានជុំវិញ

ក្រាបទី30៖កត្តាមជ្ឈដ្ឋានជុំវិញ




ក្រាបខាងលើបង្ហាញបញ្ហាប្រឈមដែលគ្រូបង្រៀនបានជួបប្រទះចំពោះមជ្ឈដ្ឋានជុំវិញដែលមាន ១០៥ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថាកម្រិតខ្សោយមាន៤២ ស្មើនឹង៤០.%។ កម្រិតមធ្យម មាន៣៦ ស្មើនឹង៣៤.២៩%។ កម្រិតល្អបង្គួរមាន១០ ស្មើនឹង៩.៥២%។ កម្រិតល្អមាន១៣ ស្មើនឹង ១២.៣៨%។ កម្រិតល្អណាស់មាន៤ ស្មើនឹង៣.៨១%។

ដូចនេះយើងឃើញថាបញ្ហាប្រឈមគឺនៅមានបញ្ហាចោទព្រោះស្ថិតនៅក្នុងកម្រិតល្អណាស់គឺ ៣.៨១%។

## ៤.៣. សិស្សានុសិស្សភាសាអង់គ្លេសថ្នាក់ទី១០ ទី១១ និងទី១២

### ៤.៣.១. ព័ត៌មានទូទៅ

តារាងទី5៖បង្ហាញអំពីព័ត៌មានលម្អិតអំពីសិស្ស

| ចំនួន | ភេទ | | អាយុ | | ថ្នាក់ទី | | |
|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ចន្លោះ | ចំនួន | ១០ | ១១ | ១២ |
| ១៦០ | ៨០ | ៨០ | [15-17] | ៦៣ | ៥៥ | ៥៧ | ៤៨ |
| | | | [18-20] | ៩៧ | | | |
| | | | [21-22] | 0 | | | |

តារាងខាងលើបង្ហាញអំពីចំនួនសិស្សនៅតាមវិទ្យាល័យទាំង៨ក្នុងស្រុកព្រៃកប្បាសដែលមានចំនួនសរុប១៦០ នាក់ ស្មើនឹង១០០%។ ដែលក្នុងនេះប្រុសមានចំនួន៨០ នាក់ស្មើនឹង៥០% និងស្រីមានចំនួន៨០ នាក់ស្មើនឹង៥០%។

ចំពោះអាយុពី១៥ឆ្នាំ ដល់១៧ឆ្នាំ មានចំនួន ៦៣នាក់ ស្មើនឹង៣៩.៣៨%។ អាយុពី១៨ឆ្នាំ ដល់២០ឆ្នាំ មានចំនួន ៩៧នាក់ ស្មើនឹង៦០.៦៣%។

ចំពោះថ្នាក់ទី១០ មានចំនួន៥៥នាក់ ស្មើនឹង៣៤.៣៨%។ ថ្នាក់ទី១១ មានចំនួន៥៧នាក់ ស្មើនឹង៣៥.៦៣%។ ថ្នាក់ទី១២ មានចំនួន៤៨នាក់ ស្មើនឹង៣០%។

## ៤.៣.២. ការយល់ឃើញរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស

ក្រាបទី31៖សារៈសំខាន់ភាសាអង់គ្លេស




ក្រាបខាងលើបង្ហាញពីការយល់ឃើញចំពោះសារៈសំខាន់ភាសាអង់គ្លេសរបស់សិស្សដែលមានចំនួន៦៣៧ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថាខ្សោយមិនមានតម្លៃលេខនោះទេ។ កម្រិតមធ្យមមានចំនួន៧ ស្មើនឹង១.១០%។ កម្រិតល្អបង្គួរមានចំនួន១៥៩ ស្មើនឹង២៤.៩៦%។ កម្រិតល្អមានចំនួន៤២៦ ស្មើនឹង៦៦.៨៨%។ កម្រិតល្អណាស់មានចំនួន៤៥ ស្មើនឹង៧.០៦%។

ដូចនេះការយល់ឃើញរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេសគឺស្ថិតនៅក្នុងកម្រិតល្អដែលមាន៦៦.៨៨%ខ្ពស់ជាងគេ។

## ៤.៣.៣. ការបង្រៀននិងរៀនសំរាប់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស

ក្រាបទី32៖ការបង្រៀននិងរៀនភាសាអង់គ្លេស




ក្រាបខាងលើបង្ហាញពីការបង្រៀននិងរៀនភាសាអង់គ្លេសចំពោះសិស្សថ្នាក់ទី១០ ទី១១ និង ទី១២សម្រាប់វិទ្យាល័យទាំង០៨ ដែលមានចំនួនសរុប១១១៣ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថា កម្រិតខ្សោយមិនមានជាតួលេខនោះទេ។ កម្រិតមធ្យមមានចំនួន១៥ ស្មើនឹង១.៣៥%។ កម្រិតល្អបង្គួរមានចំនួន៤២១ ស្មើនឹង៣៧.៨៣%។ កម្រិតល្អមានចំនួន៦៦៦ ស្មើនឹង៥៩.៨៤%។ កម្រិតល្អណាស់មានចំនួន១១ ស្មើនឹង០.៩៩%។

ដូចនេះការបង្រៀននិងរៀនភាសាអង់គ្លេសរបស់គឺស្ថិតនៅកម្រិតល្អខ្ពស់ជាងគេគឺ៥៩.៨៤%។

### ៤.៣.៣. បញ្ហាប្រឈមសំរាប់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស

ក្រាបទី33៖បញ្ហាប្រឈមរបស់សិស្ស




ក្រាបខាងលើបង្ហាញពីបញ្ហាប្រឈមរបស់សិស្សដែលកើតមានចំពោះការសិក្សាភាសាអង់គ្លេស ដែលមានចំនួន៧៩៨ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថា កម្រិតខ្សោយមានចំនួន ៦៦៣ ស្មើនឹង ៨៣.០៨%។ មធ្យមមានចំនួន១២៤ ស្មើនឹង១៥.៥៤%។ ល្អបង្គួរមានចំនួន១១ ស្មើនឹង១.៣៨%។ កម្រិតល្អនិងល្អណាស់មានមិនមានជាតម្លៃលេខទេ។

ដូចនេះបញ្ហាដែលកើតមានចំពោះសិស្សគឺមិនសូវចោទជាបញ្ហានោះទេដោយកម្រិតល្អនិងកម្រិត ល្អណាស់មិនមានបង្ហាញជាភាគរយទេ។

### ៤.៤. សរុបលទ្ធផលរួមទាំងគណៈគ្រប់គ្រងសាលា គ្រូបង្រៀនភាសាអង់គ្លេស និងសិស្សានុសិស្ស

#### ៤.៤.១. ការយល់ឃើញចំពោះមុខវិជ្ជាភាសាអង់គ្លេស

ក្រាបទី34៖ការយល់ឃើញចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់គណៈគ្រប់គ្រងសាលា




ក្រាបខាងលើនេះបង្ហាញអំពីលទ្ធផលនៃការយល់ឃើញរបស់គណៈគ្រប់គ្រងសាលាចំពោះសារៈសំខាន់នៃភាសាអង់គ្លេសដែលមានចំនួនសរុប៣៤៥ ស្មើនឹង១០០%។ តាមក្រាបបង្ហាញអោយឃើញថាកម្រិតខ្សោយមានចំនួន០។ កម្រិតមធ្យមមានចំនួន២០ ស្មើនឹង៥.៨០%។ កម្រិតល្អបង្គួរមានចំនួន៩៩ ស្មើនឹង២៨.៧០%។ កម្រិតល្អមានចំនួន១៤៩ ស្មើនឹង៤៣.១៩%។ កម្រិតល្អណាស់មានចំនួន៧៧ ស្មើនឹង២២.៣២%។

ដូចនេះយើងឃើញថាការយល់ឃើញរបស់គណៈគ្រប់គ្រងសាលាចំពោះភាសាអង់គ្លេសគឺស្ថិតនៅក្នុងកម្រិតល្អខ្ពស់ជាងគេគឺ៤៣.១៩%។

ក្រាបទី35៖ការយល់ឃើញចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់គ្រូបង្រៀន




ក្រាបខាងលើនេះបង្ហាញអំពីលទ្ធផលនៃការយល់ឃើញរបស់គ្រូបង្រៀនចំពោះសារៈសំខាន់នៃភាសាអង់គ្លេសដែលមានចំនួនសរុប៣១៥ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថាខ្សោយមានចំនួន ២០ ស្មើ៦.៣៥%។ កម្រិតមធ្យមមាន២៧ ស្មើនឹង៨.៥៧%។ កម្រិតល្អបង្គួរមានចំនួន៧៣ ស្មើនឹង ២៣.១៧%។ កម្រិតល្អមានចំនួន១០៥ ស្មើនឹង៣៣.៣៣%។ កម្រិតល្អណាស់មានចំនួន៩០ ស្មើនឹង ២៨.៥៧%។

ដូចនេះ ការយល់ឃើញរបស់គ្រូបង្រៀនចំពោះសារៈសំខាន់របស់ភាសាអង់គ្លេសគឺស្ថិតនៅកម្រិតល្អខ្ពស់ជាងគេគឺ៣៣.៣៣%។

ក្រាបទី36៖ការយល់ឃើញចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់សិស្សានុសិស្ស




ក្រាបខាងលើបង្ហាញអំពីការយល់ឃើញរបស់សិស្សានុសិស្សចំពោះសារៈសំខាន់នៃមុខវិជ្ជាភាសាអង់គ្លេសដែលមានចំនួនសរុប៦៣៧ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថា កម្រិតខ្សោយមិនមានជាចំនួនលេខនោះទេ។ កម្រិតមធ្យមមានចំនួន៧ ស្មើនឹង១.១០%។ កម្រិតល្អបង្គួរមានចំនួន១៥៩ ស្មើនឹង២៤.៩៦%។ កម្រិតល្អមានចំនួន៤២៦ ស្មើនឹង៦៦.៨៨%។ កម្រិតល្អណាស់មានចំនួន៤៥ ស្មើនឹង៧.០៦%។

ដូចនេះការយល់ឃើញរបស់សិស្សគឺស្ថិតនៅត្រង់កម្រិតល្អដែលមានភាគរយខ្ពស់ជាងគេគឺ ៦៦.៨៨%ដែលសបញ្ជាក់អោយដឹងថាសិស្សានុសិស្សពិតជាបានចាត់ទុកភាសាអង់គ្លេសថាមានសារៈសំខាន់មែន។

ក្រាបទី37៖ជាការសរុបបញ្ចូលគ្នានៃការយល់ឃើញចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់គណៈគ្រប់គ្រងសាលា និង  គ្រូបង្រៀនភាសាអង់គ្លេស




តាមក្រាបខាងលើងបង្ហាញពីការស្រង់ស្ថិតិសរុបបញ្ចូលគ្នាទាំងអស់របស់  គណៈគ្រប់គ្រងសាលា និង  គ្រូបង្រៀនភាសាអង់គ្លេស  ដែលពាក់ព័ន្ធជាមួយនិងការយល់ឃើញក៏ដូចជាចំណាប់អារម្មណ៍របស់ពួកគាត់ទៅនិងមុខវិជ្ជាភាសាអង់គ្លេស។ តាមរយៈក្រាបយើងឃើញថាសម្រាប់ការសិក្សាគិតជាមធ្យមមានត្រឹម៣៥%។  សម្រាប់ការងារគិតជាមធ្យមមានត្រឹម៣៦%។  ចំណែកសម្រាប់អនាគតគិតជាមធ្យមមានត្រឹម៣៩%។ ដូចនេះបញ្ជាក់ថាការឱ្យតម្លៃចំពោះភាសាអង់គ្លេសសម្រាប់ពួកគាត់គឺនៅមានកម្រិតទាបនៅឡើយ។

### ៤.៤.២. ការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេស

ក្រាបទី38៖ការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់គណៈគ្រប់គ្រងសាលា




ក្រាបខាងលើនេះបង្ហាញអំពីលទ្ធផលសរុបនៃការគ្រប់គ្រងការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេសដែលមានចំនួនសរុប៨៤៥ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថាកម្រិតខ្សោយមិនមានជាចំនួនតួលេខទេ។ កម្រិតមធ្យមមានចំនួន២៨ ស្មើនឹង៣.៣១%។ កម្រិតល្អបង្គួរមានចំនួន២៩៧ ស្មើនឹង៣៥.១៥%។ កម្រិតល្អមានចំនួន៤០៩ ស្មើនឹង៤៨.៤០%។ កម្រិតល្អណាស់មានចំនួន១១១ ស្មើនឹង១៣.១៤%។

ដូចនេះការគ្រប់គ្រងការបង្រៀននិងរៀនរបស់គណៈគ្រប់គ្រងសាលាគឺស្ថិតនៅក្នុងកម្រិតល្អដែលមានភាគរយខ្ពស់ជាងគេ។

ក្រាបទី39៖ការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់គ្រូបង្រៀន




ក្រាបខាងលើនេះបង្ហាញអំពីលទ្ធផលសរុបនៃការគ្រប់គ្រងការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់គ្រូបង្រៀនដែលមានចំនួនសរុប៧៣២ ស្មើនឹង១០០%។ តាមក្រាបបង្ហាញអោយឃើញថាកម្រិតខ្សោយមានចំនួន៣៩ ស្មើនឹង៥.៣៣%។ កម្រិតមធ្យមាមានចំនួន៨២ ស្មើនឹង១១.២០%។ កម្រិតល្អបង្គួរមានចំនួន២០១ ស្មើនឹង២៧.៤៦%។ កម្រិតល្អមានចំនួន២៨៨ ស្មើនឹង៣៩.៣៤%។ កម្រិតល្អណាស់មានចំនួន១២២ ស្មើនឹង១៦.៦៧%។

ដូចនេះការគ្រប់គ្រងការបង្រៀននិងរៀនរបស់លោកគ្រូអ្នកគ្រូដែលបង្រៀនមុខវិជ្ជាភាសាអង់គ្លេសគឺស្ថិតនៅក្នុងកម្រិតល្អដែលមានភាគរយខ្ពស់ជាងគេប៉ុន្តែនៅត្រង់កម្រិតខ្សោយយើងឃើញថាមានចំនួនជាតួលេខបង្ហាញដែលស្មើ៥.៣៣% ដែលជាហេតុធ្វើអោយការបង្រៀននិងរៀនរបស់លោកគ្រូអ្នកគ្រូនៅចោទជាបញ្ហានៅឡើយដែលយើងគួរដោះស្រាយ។

ក្រាបទី40៖ការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់សិស្សស្សានុសិស្ស




ក្រាបខាងលើនេះបង្ហាញអំពីលទ្ធផលសរុបនៃការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេសសម្រាប់សិស្សានុសិស្សដែលមានចំនួនសរុប១១១៣ ស្មើនឹង១០០%។ តាមក្រាបបង្ហាញថាកម្រិតខ្សោយមិនមាននោះទេ។ កម្រិតមធ្យមមានចំនួន១៥ ស្មើនឹង១.៣៥%។ កម្រិតល្អបង្គួរមានចំនួន៤២១ ស្មើនឹង៣៧.៨៣%។ កម្រិតល្អមានចំនួន៦៦៦ ស្មើនឹង៥៩.៨៤%។ កម្រិតល្អណាស់មានចំនួន១១ ស្មើនឹង០.៩៩%។

ដូចនេះការបង្រៀននិងរៀនសំរាប់សិស្សគឺស្ថិតនៅត្រង់កម្រិតល្អខ្ពស់ជាងគេប៉ុន្តែក៏នៅមានចំណុចតិចតួចដែលត្រូវកែលម្អដែរ។

ក្រាបទី41៖ជាការបញ្ចូលគ្នាទាំងគណៈគ្រប់គ្រងសាលា និង គ្រូបង្រៀន ពាក់ព័ន្ធជាមួយនិងការបង្រៀន និងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេស




តាមក្រាបខាងលើងបង្ហាញពីការស្រង់ស្ថិតិសរុបបញ្ចូលគ្នាទាំងអស់របស់ គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនភាសាអង់គ្លេស ដែលពាក់ព័ន្ធជាមួយនិងការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេស របស់ពួកគាត់ ។ តាមរយៈក្រាបយើងឃើញថាសម្រាប់សេចក្តីណែនាំគិតជាមធ្យមមានត្រឹម២៤%។ សម្រាប់សៀវភៅសិក្សាគិតជាមធ្យមមានត្រឹម៣៥%។ សម្រាប់ម៉ោងសិក្សាគិតជាមធ្យមមានត្រឹម៣៩%។ សម្រាប់សមត្ថភាពនិងទេពកោសល្យរបស់គ្រូគិតជាមធ្យមមាន៤៧%។ សម្រាប់កិច្ចតែងការបង្រៀនគិតជាមធ្យមមាន៥៣%។ សម្រាប់ការធ្វើតេស្តនិងវាយតម្លៃលទ្ធផលសិក្សាមាន២៤%។ សម្រាប់ការចុះអធិការកិច្ចគិតជាមធ្យមមាន២៩%។ សម្រាប់ការសិក្សារបស់សិស្សគិតជាមធ្យមមាន៣១%។ ដោយមធ្យមភាគទាំងអស់ស្ថិតនៅក្នុងកម្រិតភាគរយទាបដូចនេះបញ្ជាក់ថាការគ្រប់គ្រងការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេសសម្រាប់ពួកគាត់គឺនៅមានកង្វះខាតច្រើននៅឡើយ។

### ៤.៤.៣. បញ្ហាប្រឈមចំពោះមុខវិជ្ជាភាសាអង់គ្លេស

ក្រាបទី42៖បញ្ហាប្រឈមចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់នាយកសាលា




ក្រាបខាងលើបង្ហាញអំពីបញ្ហាប្រឈមដែលកើតមានចំពោះការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេសសម្រាប់នាយកសាលាដែលមានទួន៤៣៥ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថា កម្រិតខ្សោយមាន១៧៤ ស្មើនឹង៤០%។ កម្រិតមធ្យមមាន១៤៥ ស្មើនឹង៣៣.៣៣%។ កម្រិតល្អបង្គួរមាន៥៩ ស្មើនឹង១៣.៥៦%។ កម្រិតល្អមាន៤៥ ស្មើនឹង១០.៣៤%។ កម្រិតល្អណាស់មានចំនួន១២ ស្មើនឹង២.៧៦%។

ដូចនេះបញ្ហាប្រឈមចំពោះនាយកសាលាក៏នៅមានចោទជាបញ្ហាផងដែរទោះបីជាកម្រិតខ្សោយមានភាគរយខ្ពស់ជាងគេក៏ដោយ តែកម្រិតល្អនិងកម្រិតល្អណាស់នៅមានបង្ហាញជាតួលេខផងដែរ។

ក្រាបទី43៖បញ្ហាប្រឈមចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់គ្រូបង្រៀន




ក្រាបខាងលើបង្ហាញអំពីបញ្ហាប្រឈមដែលគ្រូបង្រៀនបានជួបប្រទះនៅក្នុងការបង្រៀននិងរៀនភាសាអង់គ្លេស ដែលមានចំនួនសរុប៣៩៩ ស្មើនឹង១០០%។ តាមក្រាបយើងឃើញថាកម្រតខ្សោយមានចំនួន១២៥ ស្មើនឹង៣១.៣៣%។ កម្រិតមធ្យមមាន១២៤ ស្មើនឹង៣១.០៨%។ កម្រិតល្អបង្គួរមានចំនួន៧១ ស្មើនឹង១៧.៧៩%។ កម្រិតល្អមានចំនួន៦២ ស្មើនឹង១៥.៥៤%។ កម្រិតល្អណាស់មានចំនួន១៧ ស្មើនឹង៤.២៦%។

ដូចនេះបញ្ហាប្រឈមចំពោះគ្រូបង្រៀនក៏នៅមានចោទជាបញ្ហាផងដែរដោយសារតែកម្រិតល្អនិងល្អណាស់នៅមានបង្ហាញជាតួលេខដែលជាសញ្ញាប្រាប់ថានៅមានឧបសគ្គសំរាប់គ្រូបង្រៀន។

ក្រាបទី44៖បញ្ហាប្រឈមចំពោះមុខវិជ្ជាភាសាអង់គ្លេសសំរាប់សិស្ស




ក្រាបខាងលើបង្ហាញពីបញ្ហាប្រឈមដែលសិស្សបានជួបប្រទះនៅក្នុងការសិក្សាភាសាអង់គ្លេស ដែលមានចំនួន៧៩៨ ស្មើនឹង១០០%។ តាមក្រាបយើងបានកម្រិតខ្សោយមានចំនួន៦៦៣ ស្មើនឹង ៨៣.០៨។ មធ្យមមានចំនួន១២៤ ស្មើនឹង១៥.៥៤%។ ល្អបង្គួរមានចំនួន១១ ស្មើនឹង១.៣៨%។ ល្អនិង ល្អណាស់មិនមានបង្ហាញជាចំនួនទេ។

ដូចនេះបញ្ហាប្រឈមសម្រាប់សិស្សគឺមិនសូវមានជាបញ្ហាចោទទេដោយសារតែកម្រិតខ្សោយមាន ភាគរយខ្ពស់ ចំណែកឯកម្រិតល្អនិងកម្រិតល្អណាស់បានបង្ហាញតម្លៃស្មើសូន្យ។

ក្រាបទី45៖ជាការបញ្ចូលគ្នាទាំងគណៈគ្រប់គ្រងសាលា និង គ្រូបង្រៀន ពាក់ព័ន្ធជាមួយនិងបញ្ហាប្រឈម នៃការបង្រៀននិងរៀនចំពោះមុខវិជ្ជាភាសាអង់គ្លេស




តាមក្រាបខាងលើងបង្ហាញពីការស្រង់ស្ថិតិសរុបបញ្ចូលគ្នាទាំងអស់របស់ គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសដែលពាក់ព័ន្ធជាមួយនិងបញ្ហាប្រឈមដែលកើតមានឡើងចំពោះការបង្រៀននិងការរៀនភាសាអង់គ្លេស ។ តាមរយៈក្រាបយើងឃើញថាកត្តាសាលារៀនគិតជាមធ្យមមានកម្រិត៣៩%។កត្តាគ្រូបង្រៀនគិតជាមធ្យមមាន៥២%។កត្តាសិស្សគិតជាមធ្យមមាន៤៧%។ កត្តាមជ្ឈដ្ឋានជុំវិញនិងសង្គមគិតជាមធ្យមមាន៤២%។ តាមរយៈលទ្ធផលទាំងបង្ហាញឱ្យយើងដឹងថាកត្តាទាំងបួននេះក៏នៅជាបញ្ហាប្រឈមដល់ការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេស។

ក្រាបទី46៖ជាការសរុបបញ្ចូលគ្នាទាំងគណៈគ្រប់គ្រងសាលា គ្រូបង្រៀនភាសាអង់គ្លេស និងសិស្សានុស្ស ពាក់ព័ន្ធជាមួយនិងការយល់ឃើញ ការគ្រប់គ្រងការបង្រៀននិងរៀន និងបញ្ហាប្រឈម




ក្រាបខាងលើបង្ហាញពី ការយល់ឃើញ ការគ្រប់គ្រងការបង្រៀននិងរៀន និង បញ្ហាប្រឈមចំពោះភាសាអង់គ្លេស សម្រាប់គណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងសិស្សានុសិស្ស។ តាមក្រាបយើងបានការយល់ឃើញគិតជាមធ្យមមាន៣៨%។ ការបង្រៀននិងការរៀនគិតជាមធ្យមមាន៤០%។ បញ្ហាប្រឈមគិតជាមធ្យមមាន៤០%។

ដូចនេះតាមលទ្ធផលបង្ហាញថា ការយល់ឃើញ ការគ្រប់គ្រងការបង្រៀននិងរៀន និង បញ្ហាប្រឈម នៅតែចោទជាបញ្ហានៅឡើយសម្រាប់ការគ្រប់គ្រងការបង្រៀននិងភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យក្នុងស្រុកព្រៃកប្បាសទាំងមូល។

# ជំពូក៥

# សេចក្តីសន្និដ្ឋាន

# និង

# សំណូមពរ

# ជំពូក៥៖ សេចក្ដីសន្និដ្ឋាននិងសំណូមពរ

## ៥.១. សេចក្ដីសន្និដ្ឋាន

ក្រោយពីការប្រមូលទិន្នន័យយកមកសិក្សាស្រាវនិងវិភាគទៅលើកត្តាសំខាន់ៗជាច្រើនដែលពាក់ព័ន្ធទៅលើការគ្រប់គ្រងការបង្រៀននិងរៀនស្ថិតនៅក្រោមប្រធានបទសិក្សាស្រាវជ្រាវ **ការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យៈករណីសិក្សាស្រុកព្រែកប្បាសខេត្ត** យើងអាចសន្និដ្ឋានបានជារួមថា ការគ្រប់គ្រង់ការបង្រៀននិងរៀនភាសាអង់គ្លេសនៅសាលាវិទ្យាល័យនៅក្នុងស្រុកព្រែកប្បាសនៅពុំទាន់មានភាពល្អគ្រប់គ្រាន់នៅឡើយទេ។

ដោយផ្អែកទៅលើលទ្ធផលនៃការស្រាវជ្រាវបានរកឃើញថានៅមានចំណុចមួយចំនួនដែលនៅមានភាពមិនប្រក្រតីនិងស្ថិតនៅក្នុងកម្រិតមួយដែលត្រូវមានការយកចិត្តទុកដាក់ដើម្បីកែលម្អបន្ថែមមានដូចជា៖

### ១. ការយល់ឃើញចំពោះមុខវិជ្ជាភាសាអង់គ្លេស

- សម្រាប់គណៈគ្រប់គ្រងសាលាគិតជាមធ្យមភាគគឺមានត្រឹម៣៣%។
- សម្រាប់គ្រូបង្រៀនគិតជាមធ្យមភាគគឺមានត្រឹម៤០%។
- សម្រាប់សិស្សានុសិស្ស៖ គិតជាមធ្យមមានត្រឹម៣៩%

តាមរយៈមធ្យមភាគបូកសរុបទាំងអស់មានត្រឹម៣៨%នេះបញ្ជាក់ថាការឪ្យតម្លៃចំពោះភាសាអង់គ្លេសសម្រាប់ពួកគាត់គឺនៅមានកម្រិតទាបនៅឡើយ។

### ២. ការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេស

- សម្រាប់គណៈគ្រប់គ្រងគិតជាមធ្យមមាន៣១%ដែលស្ថិតនៅក្នុងកម្រិតទាប។ ចំណុចទាំងនោះរួមមានដូចជា៖ សេចក្ដីណែនាំ សៀវភៅសិក្សាគោល ម៉ោងសិក្សា សមត្ថភាពនិងទេពកោសល្យរបស់គ្រូ កិច្ចតែងការនិងសម្ភារៈឧបទ្ទេស ការធ្វើតេស្ត ការចុះអធិការកិច្ចចំពោះគ្រូបង្រៀន និងការ

សិក្សារបស់សិស្ស។

- សម្រាប់គ្រូបង្រៀនគិតជាមធ្យមមាន៤០%ដែលស្ថិតនៅក្នុងកម្រិតទាប។ ចំណុចទាំងនោះរួមមានដូចជា៖ សេចក្តីណែនាំ សៀវភៅសិក្សាគោល ម៉ោងសិក្សា សមត្ថភាពនិងទេពកោសល្យរបស់គ្រូ កិច្ចតែងការនិងសម្ភារៈឧបទ្ទេស ការធ្វើតេស្ត ការចុះអធិការកិច្ចចំពោះគ្រូបង្រៀន និងការសិក្សារបស់សិស្ស។
- សម្រាប់សិស្សានុសិស្សគិតជាមធ្យមមាន៥០%ដែលស្ថិតនៅកម្រិតមធ្យម។ដូនេះក៏នៅមានចំណុចជាច្រើនដែលត្រូវកែលម្អផងដែរមានដូចជា៖ សេចក្តីណែនាំ សៀវភៅសិក្សាគោល ម៉ោងសិក្សា សមត្ថភាពនិងទេពកោសល្យរបស់គ្រូ កិច្ចតែងការនិងសម្ភារៈឧបទ្ទេស ការធ្វើតេស្ត ការចុះអធិការកិច្ចចំពោះគ្រូបង្រៀន និងការសិក្សារបស់សិស្ស។

តាមការបូកបញ្ចូលគ្នានូវមធ្យមភាគសរុបមាន៤០% ដែលជាកម្រិតទាបទាមទារឱ្យមានការពង្រឹងឡើងវិញ។

## ៣. បញ្ហាប្រឈមនៅក្នុងការគ្រប់គ្រងការបង្រៀននិងរៀនភាសាអង់គ្លេស

- សម្រាប់គណៈគ្រប់គ្រងសាលាគិតជាមធ្យមមាន៤៥%បង្ហាញថាការគ្រប់គ្រងរបស់នាយកសាលានៅមានជួបប្រទះជាមួយបញ្ហាប្រឈមនៅឡើយ។
- សម្រាប់គ្រូបង្រៀនគិតជាមធ្យមមាន៤៦%បង្ហាញថាការគ្រប់គ្រងរបស់គ្រូបង្រៀនបានជួបប្រទះជាមួយបញ្ហាប្រឈមផងដែរ។
- សម្រាប់សិស្សគិតជាមធ្យមមាន៣០%បង្ហាញថាការសិក្សារបស់សិស្សក៏បានជួបប្រទះជាមួយបញ្ហាប្រឈមខ្លះដែរ។

មធ្យមភាគសរុបមាន៤០% នេះបើយោងតាមកម្រងសំណួរបញ្ជាក់ថាពួកគាត់នៅជួបប្រទះនិងបញ្ហាប្រឈមនៅឡើយ។មានដូចជា៖កត្តាសាលារៀន កត្តាគ្រូបង្រៀន កត្តាសិស្សនិង កត្តាមជ្ឈដ្ឋានជុំវិញ។

## ៥.២. សំណូមពរ

តាមរយៈលទ្ធនៃការសិក្សាស្រាវជ្រាវដែលបានរកឃើញនេះ អ្នកសិក្សាស្រាវជ្រាវសុំផ្តល់នូវសំណូមពរមួយចំនួនដូចខាងក្រោមៈ

- គណៈគ្រប់គ្រងសាលាត្រូវយកចិត្តទុកដាក់ចំពោះសេចក្តីជូនដំណឹងផ្សេងៗអំពីការបង្រៀនភាសាអង់គ្លេសដើម្បីផ្សព្វផ្សាយបន្តអោយលោកគ្រូអ្នកគ្រូមានការយល់ដឹងកាន់តែច្បាស់និងអនុវត្តអោយត្រូវតាមការណែនាំ។
- គណៈគ្រប់គ្រងសាលាត្រូវគិតគូរអំពីការចែកជូននូវសៀវភៅសិក្សាគោលសំរាប់សិស្សនិងសៀវភៅណែនាំគ្រូអោយបានគ្រប់គ្រាន់និងទាន់ពេលវេលា។ ម្យ៉ាងវិញទៀតត្រូវត្រួតពិនិត្យរាល់សៀវភៅដែលបានចែកជូននិងប្រមូលមកវិញអោយបានគ្រប់ចំនួនដើម្បីប្រើប្រាស់នៅឆ្នាំបន្ទាប់ទៀត។
